ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាល
# គ្រូបង្រៀនកម្រិតឧត្តម
# (បរិញ្ញាបត្រ+២)

វិទ្យាស្ថានជាតិអប់រំ

ខែសីហា ឆ្នាំ២០២១

# បុព្វកថា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សំដៅអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើនលើគ្រប់វិស័យ ដោយបានចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១។

ដើម្បីរួមចំណែកដល់ការអភិវឌ្ឍជាតិ ក្រសួងអប់រំ យុវជន និងកីឡាបានកសាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាច្រើន ដូចជាកំណែទម្រង់សាលាគរុកោសល្យ កំណែទម្រង់នៅកម្រិតសាលារៀន និងការលើកកម្ពស់វិធីសាស្ត្របង្រៀនតាមបរិបទថ្មី។

ការពង្រឹងគុណភាពបណ្តុះបណ្តាលគ្រូបង្រៀន ជាកត្តាសំខាន់មួយរួមចំណែកក្នុងការអភិវឌ្ឍគ្រូបង្រៀនកម្រិតឧត្តម ដើម្បីធានាបានការរៀន និងបង្រៀនមានគុណភាពក្នុងក្របខណ្ឌទូទាំងប្រទេស។ ដូចនេះ ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) ត្រូវបានរៀបចំឡើង ដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ឱ្យឆ្លើយតបទៅនឹងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹម និងមានជំនឿយ៉ាងមុតមាំថា ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលនេះនឹងជួយលើកកម្ពស់សមត្ថភាពគ្រូបង្រៀនឱ្យបានពេញលេញ ក្នុងការរៀន និងបង្រៀនគ្រប់មុខវិជ្ជាឯកទេសគរុកោសល្យ និងវិធីសាស្ត្របង្រៀនស្របតាមនិន្នាការអប់រំថ្មី។

ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ក្រុមការងារ ដែលបានខិតខំអភិវឌ្ឍក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) នេះឡើង។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ សីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# អារម្ភកថា

ធនធានមនុស្សជាកម្លាំងយ៉ាងសំខាន់ សម្រាប់ធ្វើឱ្យការអភិវឌ្ឍសង្គមជាតិទទួលបានជោគជ័យ។ គោលដៅចម្បងនៃផែនការអភិវឌ្ឍសង្គមសេដ្ឋកិច្ច គឺការរៀបចំមនុស្សឱ្យក្លាយជាពលរដ្ឋពេញលេញ។ ការអប់រំជាយុទ្ធសាស្ត្រយ៉ាងសំខាន់ដើម្បីឈានទៅសម្រេចគោលដៅនេះ។

កំណែទម្រង់វិស័យអប់រំ គឺដើម្បីធានាបាននូវការលើកកម្ពស់គុណភាពអប់រំ ដែលជានិន្នាការរួមរបស់បណ្តាប្រទេសនានាក្នុងពិភពលោក។ រីឯការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល និងការបណ្តុះបណ្តាលធនធានមនុស្ស គឺជាស្នូលនៃការបង្កើនគុណភាព និងប្រសិទ្ធភាពនៃការអប់រំ។ ឈរលើស្មារតីនេះ វិទ្យាស្ថានជាតិអប់រំបានបង្កើតគណៈកម្មការរៀបចំក្របខណ្ឌកម្មវិធីបណ្តុះបណ្តាល សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម ដោយមានការសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ។

ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២)នេះ ត្រូវបានរៀបចំឡើងដោយផ្តោតលើចក្ខុវិស័យ បេសកកម្ម គោលបំណង ការកំណត់ក្រេឌីត និងរង្វាយតម្លៃលទ្ធផលសិក្សាដែលមានកញ្ចប់មុខវិជ្ជាប្រាំ រួមមានមុខវិជ្ជារួមនៃឯកទេស មុខវិជ្ជាស្នូលនៃឯកទេស មុខវិជ្ជាជម្រើស កម្មសិក្សាប្រតិបត្តិគរុកោសល្យ និងការសរសេរនិក្ខេបបទ។ តាមរយៈកម្មវិធីបណ្តុះបណ្តាលនេះ គរុនិស្សិតនឹងទទួលបានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា ជំនាញគរុកោសល្យ និងវិធីសាស្ត្របង្រៀនថ្មីៗ ស្របតាមទស្សនវិជ្ជានៃការរៀន និងបង្រៀន ដោយផ្អែកលើលទ្ធផលសិក្សា ដើម្បីប្រែក្លាយពីការបង្រៀនទៅជាការរៀនបែបសកម្មរបស់សិស្ស(ទ្រឹស្តីអប់រំបែបស្ថាបនានិយម) និងពីការផ្ទេរចំណេះដឹងទៅជាការស្ថាបនាចំណេះដឹង ការអភិវឌ្ឍបំណិន និងសីលធម៌ដែលជាមូលដ្ឋានគ្រឹះ សម្រាប់ការបង្រៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន នាពេលអនាគត។

គណៈកម្មការរៀបចំសង្ឃឹមថា ឯកសារនេះនឹងបានជាប្រយោជន៍ដ៏សំខាន់ សម្រាប់អ្នកអនុវត្តជាពិសេសគរុនិស្សិតដែលទទួលបានការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ ក្នុងការយកចំណេះដឹងនិងជំនាញទៅអនុវត្តក្នុងការបង្រៀនប្រកបដោយគុណភាព ប្រសិទ្ធភាពខ្ពស់ និងជំរុញឱ្យការអប់រំនៅកម្ពុជាមានការអភិវឌ្ឍដូចប្រទេសនានាក្នុងតំបន់ និងលើសកលលោក។

**គណៈកម្មការរៀបចំក្របខណ្ឌកម្មវិធីបណ្តុះបណ្តាល**

# គណៈកម្មការ

## ១. គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហង់ជួន ណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២- ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣- ឯកឧត្តមបណ្ឌិត | **ឌី ខាំបូលី** | ប្រធានគណៈកម្មាធិការកំណែទម្រង់នៃវ.ជ.អ. |
| ៤- ឯកឧត្តមបណ្ឌិត | **សៀង សុវណ្ណា** | នាយកវិទ្យាស្ថានជាតិអប់រំ |
| ៥- លោកជំទាវបណ្ឌិត | **ឃួន វិច្ឆិកា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ |

## ២. គណៈកម្មការនិពន្ធ រៀបរៀង និងចងក្រងសៀវភៅ

| | | |
|---|---|---|
| ១- លោកបណ្ឌិត | **ឈុក ច័ន្ទឆាយា** | អនុប្រ.គណៈកម្មាធិការកំណែទម្រង់នៃវ.ជ.អ. |
| ២- លោក | **ថៃ ហេង** | នាយករងវិទ្យាស្ថានជាតិអប់រំ |
| ៣- លោកបណ្ឌិត | **សុខ សុទ្រ** | ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំនៃស.ភ.ភ.ព. |
| ៤- លោកបណ្ឌិត | **សិត សេង** | នាយកវិ.គរុកោសល្យរាជធានីភ្នំពេញ |
| ៥- លោក | **យិន ធី** | អនុប្រធាននា.អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល |
| ៦- លោក | **កែល តារុណា** | អនុប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន |
| ៧- លោកបណ្ឌិត | **នី រដ្ឋា** | ប្រធានការិ.សិក្សានៃវិទ្យាស្ថានជាតិអប់រំ |
| ៨- លោក | **ម៉ៅ សារឿន** | ប្រធានដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ |
| ៩- លោក | **ណុប សុខា** | អនុប្រ.ការិ.នៃ នា.កិច្ចការប្រឡង |
| ១០- លោកស្រី | **ប៊ុន ជានស៊ីផល** | អនុប្រ.ការិ.នៃ នា.មធ្យមសិក្សាចំណេះទូទៅ |
| ១១- លោក | **គីម លាង** | អនុប្រ.ដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ |
| ១២- កញ្ញា | **ថ្លាង សុរិយា** | អនុប្រធានការិ.គណនេយ្យនៃវ.ជ.អ. |
| ១៣- លោកបណ្ឌិត | **អាន វ៉ូប្រាង** | អនុប្រ.ដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ |
| ១៤- លោកបណ្ឌិត | **ម៉ម សុជាតិ** | សាស្ត្រាចារ្យសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១៥- លោកស្រី | **នូ ចន្ធី** | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ |
| ១៦- កញ្ញា | **ឌិត ចាន់ថន្ធី** | អនុប្រធាននាយកដ្ឋានរដ្ឋបាល |

## ៣. គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

| | | |
|---|---|---|
| ១- លោកបណ្ឌិត | **ឈុក ច័ន្ទឆាយា** | អនុប្រ.គណៈកម្មាធិការកំណែទម្រង់នៃវជអ |
| ២- លោក | **ថៃ ហេង** | នាយករងវិទ្យាស្ថានជាតិអប់រំ |
| ៣- លោក | **ម៉ៅ សារឿន** | ប្រធានដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ |
| ៤- លោក | **ចេង ថុន** | អនុប្រ.ដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ |
| ៥- លោក | **គីម លាង** | អនុប្រ.ដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ |
| ៦- លោកបណ្ឌិត | **អាន វ៉ូប្រាង** | អនុប្រ.ដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ |

៧- ក្រុមគ្រូឧទ្ទេសអក្សរសាស្ត្រខ្មែរនៃវិទ្យាស្ថានជាតិអប់រំ

## ៤. ការីកុំព្យូទ័រ

| | | |
|---|---|---|
| ១- លោក | **ប៊ុនលី ម៉ារឌី** | អ្នកស្ម័គ្រចិត្តជួយដេប៉ាតឺម៉ង់អប់រំនៃវ.ជ.អ. |

# មាតិកា


**បុព្វកថា** ........ i

**អារម្ភកថា** ........ ii

**គណៈកម្មការ** ........ iii

**មាតិកា** ........ iv

**ជំពូក១ ព័ត៌មានទូទៅ** ........ 1

១.១- សេចក្ដីផ្ដើម ........ 1

១.២- ឈ្មោះសញ្ញាបត្រដែលទទួលបាន ........ 2

១.៣- ចក្ខុវិស័យ ........ 2

១.៤- បេសកកម្ម ........ 2

១.៥- គោលបំណង ........ 3

១.៦- លទ្ធផលសិក្សារំពឹងទុក ........ 3

១.៧- អាជីពរំពឹងទុក ........ 6

**ជំពូក២ សេចក្ដីលម្អិតកម្មវិធីបណ្ដុះបណ្ដាល** ........ 7

២.១- ប្រភេទកម្មវិធីបណ្ដុះបណ្ដាល និងចំនួនក្រេឌីត ........ 7

២.២- រចនាសម្ព័ន្ធកម្មវិធីបណ្ដុះបណ្ដាល ........ 7

២.៣- លក្ខខណ្ឌនៃការជ្រើសរើសចូលរៀន ........ 8

២.៤- មុខវិជ្ជាក្នុងកម្មវិធីបណ្ដុះបណ្ដាល ........ 9

២.៥- ការប្រឡងវាស់ស្ទង់គុណសម្បត្តិ ........ 13

២.៦- ផែនការដំណើរការកម្មវិធីបណ្ដុះបណ្ដាល ........ 13

**ជំពូក៣ គ្រូឧទ្ទេស គម្រោងស្រាវជ្រាវនិក្ខេបបទ និងការវាយតម្លៃ** ........ 16

៣.១- គ្រូឧទ្ទេសបង្រៀនមុខវិជ្ជា ........ 16

៣.២- គ្រូឧទ្ទេសណែនាំគោល និងគ្រូឧទ្ទេសណែនាំរង ........ 16

៣.៣- ការស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទ ........ 16

៣.៤- ការវាយតម្លៃការបណ្ដុះបណ្ដាល ........ 17

**ជំពូក៤ ការពណ៌នាមុខវិជ្ជា** ........ 20

៤.១- មុខវិជ្ជារួមនៃឯកទេស ........ 21

៤.២- មុខវិជ្ជាស្នូលនៃឯកទេស ........ 22

៤.៣- មុខវិជ្ជាជ្រើសរើស ........ 27

៤.៤- កម្មសិក្សាគរុកោសល្យ ........ 29

៤.៥- មុខវិជ្ជាតម្រូវ ........ 30

៤.៦- ម៉ោងសិក្សាបន្ថែម ........ 30

**ឯកសារយោង** ........ 31

# ជំពូក១
# ព័ត៌មានទូទៅ

## ១.១- សេចក្តីផ្តើម

និន្នាការនៃការអប់រំក្នុងតំបន់ និងពិភពលោក មានគោលដៅសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា និងសង្គមឌីជីថលដែលក្នុងនោះគុណភាពអប់រំ គឺជាកត្តាចម្បង។

ឆ្លើយតបទៅនឹងនិន្នាការខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលក្នុងនោះមុំទី១ ផ្តោតទៅលើការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សពិសេសអភិវឌ្ឍយុវជន ឱ្យក្លាយទៅជាពលរដ្ឋពេញលេញ មានចំណេះ និងជំនាញវិជ្ជាជីវៈច្បាស់លាស់សម្រាប់កសាងសង្គមពុទ្ធិ និងវិបុលភាព ដើម្បីចូលរួមលើកកម្ពស់សេដ្ឋកិច្ចជាតិ ប្រែក្លាយពីប្រទេសកសិកម្ម ទៅជាប្រទេសឧស្សាហកម្មនៅឆ្នាំ២០២៥ ពីប្រទេសមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។

ដើម្បីសម្រេចបាននូវគោលដៅខាងលើ ពិសេសយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡាបានកសាងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ដោយផ្តោតទៅលើការអនុវត្តគោលនយោបាយធំៗចំនួន២ ទី១ គឺធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និងទី២ គឺធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ តាមរយៈការដាក់ចេញនូវកម្មវិធីកំណែទម្រង់ស៊ីជម្រៅចំនួន១៥ចំណុច ឈរលើសសរស្តម្ភចំនួន៥ រួមមានការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ការកែលម្អកម្មវិធីបណ្តុះបណ្តាល និងសៀវភៅសិក្សាគោល ការធ្វើអធិការកិច្ចគ្រប់ជ្រុងជ្រោយ ការពង្រឹងវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងការធ្វើកំណែទម្រង់ឧត្តមសិក្សា។

ទន្ទឹមគ្នានេះដែរ ក្រសួងក៏បានបង្កើតឡើងនូវឯកសារគតិយុត្តិជាច្រើនដែលទាក់ទងទៅនឹងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន ដូចជាស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន គន្លងអាជីពគ្រូបង្រៀន និងគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

ដើម្បីអនុវត្តបេសកកម្មនេះឱ្យមានប្រសិទ្ធភាពខ្ពស់ វិទ្យាស្ថានជាតិអប់រំបានសហការជាមួយវិទ្យាស្ថានជាតិអប់រំសិង្ហបុរី ក្រោមការឧបត្ថម្ភពីគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ១(USESDP1) បានធ្វើការវាយតម្លៃកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួន ដើម្បីរកឱ្យឃើញនូវចំណុចខ្លាំង និងចំណុចគួរកែលម្អក្នុងគោលដៅធ្វើយ៉ាងណាឱ្យការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមនៅកម្ពុជា មានជំនាញសតវត្សរ៍ទី២១ ពោលគឺជំនាញត្រិះរិះពិចារណា ច្នៃប្រឌិត សហប្រតិបត្តិការ និងជំនាញប្រាស្រ័យទាក់ទង។

ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) នៃវិទ្យាស្ថានជាតិអប់រំត្រូវបានបង្កើតឡើងដោយផ្អែកលើទស្សនវិជ្ជាអប់រំ ភាពជឿជាក់ ការតម្រង់ទិស ទ្រឹស្តីនៃការរៀន និងបង្រៀន និងតម្រូវការសង្គម នាយុគសម័យឌីជីថល តាមរយៈទស្សនៈអប់រំបែបជឿនលឿន និងទស្សនវិជ្ជាអប់រំបែបស្ថាបនានិយម ដោយជឿជាក់ថា កម្មវិធីបណ្តុះបណ្តាលពហុមុខវិជ្ជានេះ នឹងផ្តោតការយកចិត្តទុកដាក់ទៅលើជំនាញទូទៅនៅក្នុងដំណាក់កាលដំបូង និងបំណិនការងារប្រតិបត្តិវិជ្ជាជីវៈនៅដំណាក់កាល

បន្ត។ កម្មវិធីបណ្តុះបណ្តាលនេះ ក៏នឹងបំពាក់មូលដ្ឋានគ្រឹះទាំងខាងផ្នែកបញ្ញត្តិ និងទ្រឹស្តីរឹងមាំដល់អ្នកសិក្សាឱ្យមានឱកាសគ្រប់គ្រាន់ ដើម្បីយកចំណេះដឹង និងបំណិនទាំងនោះទៅប្រើប្រាស់ក្នុងលក្ខខណ្ឌការងារជាក់ស្តែង។ ក្នុងន័យនេះ គ្រូបង្រៀនត្រូវបានរំពឹងថានឹងបណ្តុះភាពចង់ចេះ ចង់ដឹងរបស់អ្នកសិក្សា និងជំរុញឱ្យមានការគិតកម្រិតខ្ពស់ និងការកសាងចំណេះដឹងតាមរយៈការស្រាវជ្រាវជាក់ស្តែង ដើម្បីចូលរួមដោះស្រាយបញ្ហានានាក្នុងសង្គម និងនាំមកនូវការផ្លាស់ប្តូរប្រកបដោយភាពវិជ្ជមាន។ ការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាចម្បង សម្រាប់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយនិរន្តរភាព។ ដូច្នេះ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម ពិតជាមានសារៈសំខាន់សម្រាប់អភិវឌ្ឍគ្រូបង្រៀន ឱ្យបានគ្រប់ជ្រុងជ្រោយ ទាំងរាងកាយ បញ្ញាញាណ និងស្មារតី ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសង្គម ចំណេះដឹងប្រកបដោយនិរន្តរភាព ភាពសុខដុមរមនា និងសន្តិភាព។

## ១.២- ឈ្មោះសញ្ញាបត្រដែលទទួលបាន

ភាសាខ្មែរ៖ **បរិញ្ញាបត្រជាន់ខ្ពស់អប់រំវិជ្ជាជីវៈគ្រូបង្រៀនកម្រិតឧត្តម**

ភាសាអង់គ្លេស៖ Master's Degree of Education in Upper-Secondary School Teaching

## ១.៣- ចក្ខុវិស័យ

ចក្ខុវិស័យនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) គឺកសាងជួរគ្រូបង្រៀនឱ្យមានសមត្ថភាពជំនាញសតវត្សរ៍ទី២១ ដោយផ្តោតលើចំណេះដឹងវិជ្ជាជីវៈ ជំនាញវិជ្ជាជីវៈ ក្រមសីលធម៌វិជ្ជាជីវៈ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីអភិវឌ្ឍធនធានមនុស្ស ឱ្យមានលក្ខណៈសម្បត្តិពេញលេញសម្រាប់កសាងសង្គមពុទ្ធិ និងវិបុលភាព។

## ១.៤- បេសកកម្ម

បេសកកម្មនៃការបណ្តុះបណ្តាលគឺ៖

ក. បណ្តុះទស្សនវិជ្ជាអប់រំក្នុងការរៀន និងបង្រៀន

ខ. ផ្តល់សេវាបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម ឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ប្រកបដោយគុណភាព

គ. លើកកម្ពស់សមត្ថភាព ការយល់ដឹងពីនិន្នាការអប់រំ និងការវិវត្តនៃការអប់រំថ្មីៗកម្រិតជាតិ តំបន់ និងសកលលោក

ឃ. ផ្តល់ចំណេះដឹងឯកទេស វិធីសាស្ត្របង្រៀន ការគ្រប់គ្រងថ្នាក់រៀន បំណិនក្នុងការបង្រៀន និងគរុកោសល្យថ្មីៗ តាមការសិក្សាបែបសកម្ម និងតាមទ្រឹស្តីអប់រំបែបស្ថាបនានិយម ក្នុងបរិបទសតវត្សរ៍ទី២១ តាមរយៈការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង

ង. បណ្តុះជំនាញស្រាវជ្រាវ ការផលិតសម្ភារឧបទេសរៀននិងបង្រៀន ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងវប្បធ៌មការសិក្សាពេញមួយជីវិត

ច. ផ្តល់ជំនាញប្រើប្រាស់បច្ចេកវិទ្យា ភាសាបរទេស ការវាយតម្លៃ និងការពិនិត្យតាមដានក្នុងការរៀន និងបង្រៀន

ឆ. កសាងឧត្តមភាពគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងជំនាញសតវត្សរ៍ទី២១

ជ. ផ្តល់ជំនាញប្រឹក្សាគរុកោសល្យ។

## ១.៥- គោលបំណង

កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) មានគោលបំណងបណ្តុះបណ្តាលអ្នកសិក្សាឱ្យក្លាយទៅជា៖

- PEO1: គ្រូបង្រៀនកម្រិតឧត្តមប្រកបដោយសមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់
- PEO2: អ្នកស្រាវជ្រាវអប់រំដែលមានការអភិវឌ្ឍ ការអនុវត្ត និងការវាយតម្លៃការសិក្សារបស់សិស្សប្រកបដោយសមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់។

## ១.៦- លទ្ធផលរំពឹងទុក

នៅពេលបញ្ចប់ការបណ្តុះបណ្តាល គរុនិស្សិតកម្រិតឧត្តម(បរិញ្ញាបត្រ+២) នឹងទទួលបាននូវកញ្ចប់សមត្ថភាពដូចខាងក្រោម៖

### ក- ចំណេះដឹង

- PLO1: រៀបរាប់ពីចំណុចសំខាន់ៗស្តីពីកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន រួមមានទស្សនវិជ្ជា ចិត្តវិទ្យា ទ្រឹស្តី គោលការណ៍ និងទស្សនាទាននៃកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន ជាមូលដ្ឋានគ្រប់កម្រិតថ្នាក់។
- PLO2: ពន្យល់ពីទស្សនវិជ្ជាអប់រំ ចិត្តវិទ្យាអប់រំ ប្រវត្តិអប់រំ ច្បាប់អប់រំ មូលដ្ឋានសង្គមនៃការអប់រំ និងការវិវត្តចុងក្រោយនៃការអប់រំ ជាពិសេសការអប់រំគ្រូបង្រៀនសតវត្សរ៍ទី២១។
- PLO3: ពណ៌នាពីការអភិវឌ្ឍជំនាញឯកទេស និងវិធីសាស្ត្របង្រៀនដែលមានឥទ្ធិពលទៅលើការអនុវត្តវិជ្ជាជីវៈក្នុងវិស័យអប់រំ។
- PLO4: ប្រើប្រាស់វិធីសាស្ត្របង្រៀន និងគរុកោសល្យសតវត្សរ៍ទី២១។

### ខ- ជំនាញការគិតវិភាគ

- PLO5: ស្រាវជ្រាវលើការងារផ្នែកឯកទេសនិងវិធីសាស្ត្របង្រៀន និងផលិតសម្ភារឧបទេសដើម្បីបង្កើតចំណេះដឹងថ្មីៗ និងដោះស្រាយបញ្ហាផ្សេងៗក្នុងការអភិវឌ្ឍ ការអនុវត្ត និងការវាយតម្លៃការរៀន និងបង្រៀន ប្រកបដោយគំនិតច្នៃប្រឌិតនិងនិរន្តរភាព តាមរយៈការសិក្សាពេញមួយជីវិត។
- PLO6: វិភាគនិងសំយោគគោលវិធី ទ្រឹស្តី ជំនាញគរុកោសល្យ ការគ្រប់គ្រងថ្នាក់ ការប្រើប្រាស់ទ្រឹស្តីនៃការរៀន និងបង្រៀនសមស្រប។

### គ- ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ

- PLO7: ប្រព្រឹត្តយ៉ាងសមស្របប្រកបដោយស្វ័យភាពនិងការផ្តួចផ្តើមគំនិតកម្រិតខ្ពស់ក្នុងសកម្មភាពទាក់ទងទៅនឹងការអនុវត្តវិធីសាស្ត្ររៀន និងបង្រៀន។
- PLO8: សម្របសម្រួលនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការធ្វើការងារជាក្រុម និងអនុវត្តយ៉ាងមានប្រសិទ្ធភាពក្នុងភាពជាអ្នកដឹកនាំក្នុងវិជ្ជាជីវៈផ្នែកឯកទេសវិធីសាស្ត្របង្រៀន។
- PLO9: ស្រាវជ្រាវនិងស្វែងរកឫសគល់នៃបញ្ហាទាក់ទងនឹងវិធីសាស្ត្ររៀន និងបង្រៀនដើម្បីលើកកម្ពស់គុណភាពនៃការរៀន និងបង្រៀន។
- PLO10: មានបុគ្គលិកលក្ខណៈល្អ មានទេពកោសល្យ មានការទទួលខុសត្រូវ គោរពពេលវេលា និងជាបុគ្គលគំរូ។

- PLO11: មានក្រមសីលធម៌វិជ្ជាជីវៈសម្រាប់ធ្វើជាគំរូល្អក្នុងគ្រួសារ សាលារៀន និងសហគមន៍
- PLO12: មានឧត្តមគតិ និងមនសិការវិជ្ជាជីវៈខ្ពស់។
- PLO13: មានការអភិវឌ្ឍវិជ្ជាជីវៈ និងការសិក្សាពេញមួយជីវិត តាមរយៈការផ្លាស់ប្តូរបទពិសោធ និងការចូលរួមសកម្មភាពផ្សេងៗ។
- PLO14: មានភាពឧស្សាហ៍ព្យាយាមក្នុងការស្រាវជ្រាវ ការបង្ហាញ និងការចែករំលែកស្នាដៃក្នុងវេទិកាអប់រំថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។

## ឃ- ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង

- PLO15: មានបំណិនក្នុងការប្រើប្រាស់ភាសានិងបច្ចេកវិទ្យាក្នុងការងារទំនាក់ទំនង ការស្វែងរកព័ត៌មានផ្នែកឯកទេស និងវិធីសាស្ត្ររៀន និងបង្រៀន។
- PLO16: មានបំណិនក្នុងការរៀបចំគម្រោង ការសរសេររបាយការណ៍ ការធ្វើបទបង្ហាញផ្លូវការ និងមិនផ្លូវការ និងការធ្វើរបាយការណ៍គម្រោង ប្រកបដោយតម្លាភាពនិងការទទួលខុសត្រូវ។
- PLO17: ប្រើប្រាស់និងវិភាគយ៉ាងមានប្រសិទ្ធភាពនូវព័ត៌មាន ទិន្នន័យ និងស្ថិតិតាមឯកទេសនីមួយៗ។
- PLO18: មានសមត្ថភាពទាក់ទងនឹងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) និងប្រើប្រាស់ឧបករណ៍ឌីជីថល សម្រាប់ជំនួយដល់ការរៀន ការបង្រៀន និងការស្រាវជ្រាវ។
- PLO19: មានទំនាក់ទំនងល្អជាមួយគណៈគ្រប់គ្រង គ្រូបង្រៀន សហការី មាតាបិតា អ្នកអាណាព្យាបាលសិស្ស និងសហគមន៍។

## ង- ជំនាញចិត្តចលនា

- PLO20: រៀបចំកិច្ចតែងការបង្រៀន កម្មវិធីសិក្សា និងការវាយតម្លៃដែលសមស្របនិងប្រកបដោយប្រសិទ្ធភាព
- PLO21: ផលិតនិង/ឬកែលម្អសម្ភារឧបទេសនិងសន្លឹកកិច្ចការ ដើម្បីបង្កើនលទ្ធផលសិក្សារំពឹងទុករបស់សិស្ស
- PLO22: ផ្តល់នូវបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងអំណោយផល ដែលអាចឱ្យសិស្សបញ្ចេញនូវសក្តានុពលរៀនសូត្រឱ្យអស់ពីសមត្ថភាព
- PLO23: អនុវត្តសកម្មភាពសមស្រប ដើម្បីជួយសម្រួលដល់របៀបរៀននិងតម្រូវការសិក្សារបស់សិស្សតាមរយៈវិធីសាស្ត្រចម្រុះនិងបត់បែន
- PLO24: ផ្តល់ឱកាសដល់សិស្សចូលរួមដោះស្រាយបញ្ហាដោយប្រើកម្លាំង និងបញ្ញាស្មារតីតាមរយៈការគិតបែបស៊ីជម្រៅនិងច្នៃប្រឌិត
- PLO25: អនុវត្តការវាយតម្លៃជាក់ស្តែងដែលតម្រូវឱ្យសិស្សធ្វើកិច្ចការដែលមានលក្ខណៈប្រហាក់ប្រហែលទៅនឹងស្ថានភាពរស់នៅប្រចាំថ្ងៃ

តារាងបន្សីគ្នារវាងលទ្ធផលរំពឹងទុក (PLOs) Domains and levels of revised Bloom's Taxonomy សំណុំលទ្ធផលនៃក្របខណ្ឌគុណវុឌ្ឍិជាតិ (CQF) និងគោលបំណងនៃកម្មវិធីសិក្សា (PEOs)

| លទ្ធផលរំពឹងទុក (PLOs) | Domains of revised Bloom's Taxonomy | សំណុំលទ្ធផលនៃក្របខណ្ឌគុណវុឌ្ឍិជាតិ (CQF) | គោលបំណងនៃកម្មវិធីសិក្សា (PEOs) |
|---|---|---|---|
| PLO1 | Cognitive 1 | ចំណេះដឹង | PEO1 |
| PLO2 | Cognitive 1 | ចំណេះដឹង | PEO1 |
| PLO3 | Cognitive 1 | ចំណេះដឹង | PEO1 |
| PLO4 | Cognitive 2 | ចំណេះដឹង | PEO1 |
| PLO5 | Cognitive 5<br>Affective 5 | ជំនាញការគិតវិភាគ | PEO1, PEO2 |
| PLO6 | Cognitive 4 | ជំនាញការគិតវិភាគ | PEO1, PEO2 |
| PLO7 | Cognitive 6<br>Affective 5 | ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ | PEO1 |
| PLO8 | Affective 5 | ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ | PEO1 |
| PLO9 | Cognitive 5<br>Affective 5 | ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ | PEO1, PEO2 |
| PLO10 | Affective 5 | ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ | PEO1 |
| PLO11 | Affective 5 | ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ | PEO1 |
| PLO12 | Affective 5 | ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ | PEO1 |
| PLO13 | Affective 5 | ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ | PEO1 |
| PLO14 | Affective 5 | ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ | PEO1 |
| PLO15 | Cognitive 3<br>Attitude 5 | ជំនាញលេខនព្វន្ធ ព័ត៌មានវិទ្យា និងទំនាក់ទំនង | PEO1, PEO2 |
| PLO16 | Cognitive 3<br>Affective 5 | ជំនាញលេខនព្វន្ធ ព័ត៌មានវិទ្យា និងទំនាក់ទំនង | PEO1, PEO2 |
| PLO17 | Cognitive 4<br>Affective 4 | ជំនាញលេខនព្វន្ធ ព័ត៌មានវិទ្យា និងទំនាក់ទំនង | PEO1, PEO2 |

| | | | |
|---|---|---|---|
| PLO18 | Cognitive 3 | ជំនាញលេខនព្វន្ធ ព័ត៌មានវិទ្យា និងទំនាក់ទំនង | PEO1, PEO2 |
| PLO19 | Affective 5 | ជំនាញលេខនព្វន្ធ ព័ត៌មានវិទ្យា និងទំនាក់ទំនង | PEO1 |
| PLO20 | Cognitive 6 | ជំនាញចិត្តចលនា | PEO1 |
| PLO21 | Cognitive 6 | ជំនាញចិត្តចលនា | PEO1 |
| PLO22 | Affective 5 | ជំនាញចិត្តចលនា | PEO1 |
| PLO23 | Cognitive 3<br>Affective 5 | ជំនាញចិត្តចលនា | PEO1 |
| PLO24 | Affective 5 | ជំនាញចិត្តចលនា | PEO1 |
| PLO25 | Cognitive 5 | ជំនាញចិត្តចលនា | PEO1 |

## ១.៧- អាជីពរំពឹងទុក

គរុនិស្សិតកម្រិតឧត្តម(បរិញ្ញាបត្រ+២) នឹងក្លាយជាគ្រូបង្រៀនកម្រិតឧត្តម និងអ្នកស្រាវជ្រាវអប់រំប្រកបដោយគុណភាព ដើម្បីរួមសុខដុមរមនាទាំងអស់គ្នានាពេលអនាគត។

# ជំពូក២
# សេចក្ដីលម្អិតកម្មវិធីបណ្ដុះបណ្ដាល

## ២.១- ប្រភេទកម្មវិធីបណ្ដុះបណ្ដាល និងចំនួនក្រេឌីត

ក្របខណ្ឌកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតឧត្ដម(បរិញ្ញាបត្រ+២) របស់វិទ្យាស្ថានជាតិអប់រំ ជាកម្មវិធីបណ្ដុះបណ្ដាលសម្រាប់និស្សិត ឬបុគ្គលិកអប់រំ ដែលបានបញ្ចប់សញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ យ៉ាងតិច១២០ក្រេឌីត។

## ២.២- រចនាសម្ព័ន្ធកម្មវិធីបណ្ដុះបណ្ដាល

តារាងទី១ បណ្ដុំមុខវិជ្ជា និងចំនួនក្រេឌីតតាមប្រភេទនៃការបណ្ដុះបណ្ដាល

| ល.រ. | ក្រុមមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|---|
| ១ | មុខវិជ្ជារួមនៃឯកទេស | ១៧ |
| ២ | មុខវិជ្ជាស្នូលនៃឯកទេស | ១៥ |
| ៣ | មុខវិជ្ជាជម្រើស | ៦ |
| ៤ | កម្មសិក្សាប្រតិបត្តិគរុកោសល្យ | ៤ |
| ៥ | ការសរសេរនិក្ខេបបទ | ៦ |
| | សរុប | ៤៨ |

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ មានកម្មវិធីបណ្ដុះបណ្ដាលរយៈពេល២ឆ្នាំសិក្សា និងមានចំនួនក្រេឌីតសរុប៤៨ក្រេឌីត។

### ២.២.១- ការកំណត់ក្រេឌីតនៃការបណ្ដុះបណ្ដាល

ចំនួនក្រេឌីតនៃកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតឧត្ដម(បរិញ្ញាបត្រ+២) ត្រូវបែងចែកជា៣ប្រភេទដូចខាងក្រោម៖

**ការសិក្សាទ្រឹស្ដី** មួយក្រេឌីតនៃការបណ្ដុះបណ្ដាលទ្រឹស្ដី គឺជាការបង្រៀននៅក្នុងថ្នាក់រៀនរយៈពេល០១ម៉ោង/សប្ដាហ៍ ឬចំនួនមិនតិចជាង១៥ម៉ោង/ឆមាស។

**ការសិក្សាប្រតិបត្តិ** មួយក្រេឌីតនៃការបណ្ដុះបណ្ដាលប្រតិបត្តិ គឺការហ្វឹកហាត់ ឬការធ្វើពិសោធនៅក្នុងទីពិសោធ មានរយៈពេលយ៉ាងតិច២ម៉ោង/សប្ដាហ៍ ឬមានចំនួនមិនតិចជាង៣០ម៉ោង/ឆមាស។

**ការអនុវត្តជាក់ស្ដែង** មួយក្រេឌីតនៃការបណ្ដុះបណ្ដាលអនុវត្តជាក់ស្ដែង គឺជាការបណ្ដុះបណ្ដាលនៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន ឬកន្លែងអនុវត្តជាក់ស្ដែងផ្សេងៗទៀត ដែលមានរយៈពេលយ៉ាងតិច០៣ម៉ោង/សប្ដាហ៍ ឬមានចំនួនមិនតិចជាង៤៥ម៉ោង/ឆមាស។

សម្រាប់ការអនុវត្តរូបមន្តនៃការកំណត់ក្រេឌីតសម្រាប់ការបណ្ដុះបណ្ដាល ត្រូវអនុវត្តតាមគំរូរូបមន្តដូចក្នុងតារាងទី២។

តារាងទី២ ការអនុវត្តរូបមន្តនៃការកំណត់ក្រេឌីតសម្រាប់ការបណ្ដុះបណ្ដាល

| | (លេខកូដមុខវិជ្ជា) | ឈ្មោះមុខវិជ្ជា | ចំនួនក្រេឌីត(X-Y-Z) |
|---|---|---|---|
| ឧទាហរណ៍ | 101203 | គរុកោសល្យ | ៣(២-២-៥) |
| | 101405 | សិល្បៈ និងវប្បធម៌ខ្មែរ | ២(១-២-៣) |

| | |
|---|---|
| ចំនួនក្រេឌីត | ចំនួន១ ២ ឬ៣ក្រេឌីត<br>X ចំនួនម៉ោងសិក្សាទ្រឹស្តី<br>Y ចំនួនម៉ោងសិក្សាប្រតិបត្តិ ឬចំនួនម៉ោងកម្មសិក្សា(សម្រាប់មុខវិជ្ជាកម្មសិក្សា)<br>Z ស្វ័យសិក្សា |

តារាងទី៣ ការប្តូរចំនួនក្រេឌីតទៅចំនួនម៉ោងសិក្សាក្នុងមួយសប្តាហ៍

| **ការប្តូរក្រេឌីតទៅជាចំនួនម៉ោងសិក្សា** | | |
|---|---|---|
| | **ចំនួនក្រេឌីត** | **ចំនួនម៉ោង** |
| ការសិក្សាទ្រឹស្តី | ១ ក្រេឌីត | ១ម៉ោង/សប្តាហ៍ |
| ការសិក្សាប្រតិបត្តិ ឬកម្មសិក្សា | ១ ក្រេឌីត | ២ម៉ោង/សប្តាហ៍ |
| **ការប្តូរចំនួនម៉ោងការសិក្សាទៅជាចំនួនម៉ោងស្វ័យសិក្សា** | | |
| | **ចំនួនម៉ោង** | **ចំនួនម៉ោងស្វ័យសិក្សា** |
| ការសិក្សាទ្រឹស្តី | ១ម៉ោង/សប្តាហ៍ | ២ម៉ោង/សប្តាហ៍ |
| ការសិក្សាប្រតិបត្តិ ឬកម្មសិក្សា | ១ម៉ោង/សប្តាហ៍ | កន្លះម៉ោង/សប្តាហ៍ |

ឧទាហរណ៍ទី១ មុខវិជ្ជា A ផ្តោតលើការសិក្សាទ្រឹស្តីតែម្យ៉ាងគត់ចំនួន៣ក្រេឌីត ត្រូវសរសេរ ៣(៣-០-៦)។

ឧទាហរណ៍ទី២ មុខវិជ្ជា B ចំនួន៣ក្រេឌីត សិក្សាទ្រឹស្តីចំនួន២ក្រេឌីត និងការសិក្សាប្រតិបត្តិចំនួន១ក្រេឌីត ត្រូវសរសេរ ៣(២-២-៥)។

ឧទាហរណ៍ទី៣ មុខវិជ្ជា C សរុបចំនួន៣ក្រេឌីត ផ្តោតលើការសិក្សាប្រតិបត្តិតែម្យ៉ាងគត់ ត្រូវសរសេរ៣ក្រេឌីត ៣(០-៦-៣)។

ដើម្បីបញ្ចប់វគ្គបណ្តុះបណ្តាលនេះ អ្នកសិក្សាត្រូវរៀនលើ៥ផ្នែកធំៗរួមមាន មុខវិជ្ជារួមនៃឯកទេស (១៧ក្រេឌីត) មុខវិជ្ជាស្នូលនៃឯកទេស[១៥ក្រេឌីត (ឯកទេស៦ក្រេឌីត វិធីសាស្ត្របង្រៀន៦ក្រេឌីត និងហ្វឹកហ្វឺនគរុកោសល្យ៣ក្រេឌីត)] មុខវិជ្ជាជម្រើស(៦ក្រេឌីត) កម្មសិក្សាប្រតិបត្តិគរុកោសល្យ(៤ក្រេឌីត) និងការសរសេរនិក្ខេបបទ(៦ក្រេឌីត) ជាមួយកញ្ចប់មុខវិជ្ជាពីរទៀត ដោយមិនផ្តល់ក្រេឌីតជូនទេ។

### ២.២.២- រយៈពេល និងកាលវិភាគនៃកម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាលនេះ មានរយៈពេល២ឆ្នាំ។ មួយឆ្នាំសិក្សាចែកជាពីរឆមាស។ មួយឆមាសមានចំនួនយ៉ាងតិច១៥សប្តាហ៍ ដោយមិនរាប់បញ្ចូលរយៈពេលនៃសប្តាហ៍ប្រឡង កម្មសិក្សាគរុកោសល្យ ការតាំងពិព័រណ៍អប់រំ បាឋកថានានារបស់វាគ្មិន សិក្ខាសាលា ដំណើរទស្សនកិច្ចសិក្សា និងសកម្មភាពផ្សេងៗ។ គរុនិស្សិតទាំងអស់ត្រូវសិក្សាចំនួនពី៥-៦ថ្ងៃ/សប្តាហ៍។

## ២.៣- លក្ខខណ្ឌនៃការជ្រើសរើសចូលរៀន

ការដាក់ពាក្យចូលសិក្សាក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) បេក្ខជនទាំងពីរភេទ ត្រូវបំពេញលក្ខខណ្ឌចូលរៀនគ្រប់ចំណុច ដែលបានកំណត់ដោយគណៈកម្មការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលដូចខាងក្រោម៖

-ជានិស្សិតសុទ្ធសាធដែលពុំទាន់មានការងារក្នុងក្របខណ្ឌមន្ត្រីរាជការ

-ជាបុគ្គលិកក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា

-មានសញ្ជាតិខ្មែរ មានជីវប្រវត្តិច្បាស់លាស់ និងមានសុខភាពល្អ

-ជានិស្សិត ឬបុគ្គលិកអប់រំដែលបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដោយជោគជ័យ

-ជានិស្សិត ឬបុគ្គលិកអប់រំដែលមានសញ្ញាបត្រសមមូលនឹងថ្នាក់បរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានលក្ខណសម្បត្តិបន្ថែមផ្សេងៗទៀត ដែលកំណត់ដោយគណៈកម្មការជ្រើសរើសគរុនិស្សិត។

## ២.៤- មុខវិជ្ជាក្នុងកម្មវិធីបណ្តុះបណ្តាល

### ២.៤.១- មុខវិជ្ជារួមនៃឯកទេស

| | |
|---|---|
| ១- ទស្សនវិជ្ជាអប់រំ ( Educational Philosophy ) | ២ ( ២-០-៤ ) |
| ២- ចិត្តវិទ្យា ( Psychology ) | ៣ ( ៣-០-៦ ) |
| ៣- គរុកោសល្យ ( Pedagogy ) | ៣ ( ៣-០-៦ ) |
| ៤- ស្រាវជ្រាវអប់រំ ( Educational Research ) | ៣ ( ៣-០-៦ ) |
| ៥- បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការរៀន និងបង្រៀន ( Digital Portfolio ) | ៣ ( ២-២-៥ ) |
| ៦- ការវាយតម្លៃលទ្ធផលសិក្សា ( Assessment ) | ៣ ( ៣-០-៦ ) |

### ២.៤.២- មុខវិជ្ជាស្នូលនៃឯកទេស

| | |
|---|---|
| ១- ឯកទេស១[1] ( Major 1 ) | ៣ ( ២-២-៥ ) |
| ២- ឯកទេស២ ( Major 2 ) | ៣ ( ២-២-៥ ) |
| ៣- វិធីសាស្ត្របង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ១ ( Teaching Methodology and Peer Teaching 1 ) | ៣ ( ២-២-៥ ) |
| ៤- វិធីសាស្ត្របង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ២ ( Teaching Methodology and Peer Teaching 2 ) | ៣ ( ២-២-៥ ) |
| ៥- វិធីសាស្ត្របង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ៣ ( Teaching Methodology and Peer Teaching 3 ) | ៣ ( ២-២-៥ ) |

### ២.៤.៣- មុខវិជ្ជាជម្រើស

| | |
|---|---|
| ១- សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងរដ្ឋបាលអប់រំ ( Teacher's Codes of Conduct and Education Administration ) | S/U ( ២-០-៤ ) |
| ២- សិល្បៈ និងវប្បធម៌ ( Arts and Culture ) | S/U ( ១-២-៣ ) |
| ៣- ប្រឹក្សាគរុកោសល្យ ( Pedagogical Mentoring ) | ២ ( ២-០-៤ ) |
| ៤- និន្នាការអប់រំ និងការអប់រំពេលវេញពេញលេញ ( Social Contexts of Education ) | ២ ( ២-០-៤ ) |
| ៥- ភាសាអង់គ្លេស ឬភាសាបារាំង ( English and French ) | ២ ( ២-០-៤ ) |

[1] និស្សិតសិក្សាផ្តោតលើតែមួយមុខវិជ្ជាឯកទេសដោយតម្រូវឱ្យសិក្សាជា២មុខវិជ្ជា ( Courses ) ៖ ឯកទេស១ និងឯកទេស២

**២.៤.៤- កម្មសិក្សាប្រតិបត្តិគរុកោសល្យ**( Practicum )

| | |
|---|---|
| ១- កម្មសិក្សាសង្កេត និងពាក់កណ្ដាលប្រតិបត្តិ | ១( ០-៣-២ ) |
| ២- កម្មសិក្សាប្រតិបត្តិ | ៣( ០-៦-៣ ) |

**២.៤.៥- ការសរសេរនិក្ខេបបទ**( Thesis )

| | |
|---|---|
| ១- ការសរសេរនិក្ខេបបទ១ | ៣ក្រេឌីត |
| ២- ការសរសេរនិក្ខេបបទ២ | ៣ក្រេឌីត |

## ទំនាក់ទំនងរវាងមុខវិជ្ជា និងលទ្ធផលរំពឹងទុកនៃកម្មវិធីសិក្សា ( PLOs )

| មុខវិជ្ជា | PLOs | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 |
| **មុខវិជ្ជារួមនៃឯកទេស** | | | | | | | | | | | | | | | | | | | | | | | | | |
| ១- ទស្សនវិជ្ជាអប់រំ | F | F | | M | | M | | | | | | | | | | | | | | | | P | M | | |
| ២- ចិត្តវិទ្យា | F | F | | M | | M | P | | P | | | | | | | | | | | F | F | F | F | F | F |
| ៣- គរុកោសល្យ | F | F | | | | F | F | M | P | M | P | P | P | P | M | P | | | P | F | F | F | F | F | F |
| ៤- ស្រាវជ្រាវអប់រំ | | | M | | F | | | | F | | | | | F | F | F | F | F | | P | P | | | | |
| ៥- បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការរៀននិងបង្រៀន | | | | M | | | | | | | | | | | F | F | F | F | | | | | | | |
| ៦- ការវាយតម្លៃលទ្ធផលសិក្សា | | | | | F | P | | | | | | | | | | | | | | F | | | | P | F |
| **មុខវិជ្ជាស្នូលនៃឯកទេស** | | | | | | | | | | | | | | | | | | | | | | | | | |
| ១- ឯកទេស | | | | | M | | | F | | | | | | | F | | F | | | F | F | F | F | F | F |
| ២- វិធីសាស្ត្របង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ | | | F | F | F | F | F | F | F | | | | | | F | | | F | | F | F | F | F | F | F |
| **មុខវិជ្ជាជម្រើស** | | | | | | | | | | | | | | | | | | | | | | | | | |
| ១- សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងរដ្ឋបាលអប់រំ | | | | | | | F | F | | F | F | F | F | F | | | | | F | | | | | M | |
| ២- សិល្បៈនិងវប្បធម៌ | | | | | | | | | | | | | | P | | | | | | | M | | | | |

| | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣- ប្រឹក្សាគរុកោសល្យ | | | F | F | P | | M | | M | M | P | P | P | P | | | | | P | P | P | P | M | M | M |
| ៤- និន្នាការអប់រំ និងការអប់រំពលរដ្ឋពេញលេញ | F | F | | P | | | | | | | F | | F | F | | | | | | | | | | | M |
| ៥- ភាសាអង់គ្លេស ឬភាសាបារាំង | | | | P | P | | | | P | | | | | | F | M | P | M | | | | | | | |

**កំណត់សម្គាល់៖**

- P (Partially fulfiled): ១០%-៣៩% សកម្មភាពបង្រៀននិងរៀន សកម្មភាពស្រាវជ្រាវ ឬសកម្មភាពអប់រំផ្សេងៗបានគាំទ្រលទ្ធផលសិក្សានៃកម្មវិធីបណ្តុះបណ្តាល (PLOs)
- M (Moderately fulfiled): ៤០%-៦៩% សកម្មភាពបង្រៀននិងរៀន សកម្មភាពស្រាវជ្រាវ ឬសកម្មភាពអប់រំផ្សេងៗបានគាំទ្រលទ្ធផលសិក្សានៃកម្មវិធីបណ្តុះបណ្តាល (PLOs)
- F (Fully fulfiled): ៧០%-១០០% សកម្មភាពបង្រៀននិងរៀន សកម្មភាពស្រាវជ្រាវ ឬសកម្មភាពអប់រំផ្សេងៗបានគាំទ្រលទ្ធផលសិក្សានៃកម្មវិធីបណ្តុះបណ្តាល (PLOs)

## ២.៥- ការប្រឡងវាស់ស្ទង់គុណសម្បត្តិ

គរុនិស្សិតនឹងត្រូវប្រកាសថា មានសិទ្ធិប្រឡងចេញ លុះត្រាតែបានមធ្យមពិន្ទុនៃការប្រឡងបញ្ចប់តាមមុខវិជ្ជានីមួយៗចាប់ពីមធ្យមពិន្ទុ៦៥.០០% ឬGPA2.50 ឡើងទៅ។ សម្រាប់ការប្រឡងចេញ គរុនិស្សិតដែលប្រឡងជាប់ត្រូវបានកំណត់ដោយប្រើពាក្យពេញចិត្ត(S = Satisfied) ចំណែកឯគរុនិស្សិតដែលប្រឡងធ្លាក់ត្រូវបានកំណត់ដោយប្រើពាក្យមិនពេញចិត្ត(U = Unsatisfied)។

## ២.៦- ផែនការដំណើរការកម្មវិធីបណ្តុះបណ្តាល

### ២.៦.១- ពេលវេលាដំណើរការនៃកម្មវិធីបណ្តុះបណ្តាល

កិច្ចដំណើរការកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) រៀបចំឡើងជាថ្នាក់ពេញម៉ោងដែលមានរយៈពេល២ឆ្នាំ។

កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) ជាកម្មវិធីដែលដំណើរការបង្រៀនចំនួន២ឆមាស/ឆ្នាំសិក្សា។ ក្នុង១ឆមាសមានរយៈពេលយ៉ាងតិច១៥សប្តាហ៍ ដោយកំណត់កាលបរិច្ឆេទសិក្សាដូចខាងក្រោម៖

ឆមាសទី១ វិច្ឆិកា-មេសា (អាចផ្លាស់ប្តូរតាមភាពជាក់ស្តែង)

ឆមាសទី២ ឧសភា-តុលា (អាចផ្លាស់ប្តូរតាមភាពជាក់ស្តែង)

### ២.៦.២- ការចុះឈ្មោះចូលរៀនក្នុងឆមាសនីមួយៗ

#### ២.៦.២.១- ឆ្នាំទី១

រចនាសម្ព័ន្ធកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២)នៅវិទ្យាស្ថានជាតិអប់រំសម្រាប់សិក្សាឆ្នាំទី១ ត្រូវបានបង្ហាញក្នុងតារាងខាងក្រោម៖

**ឆមាសទី១**

| លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | ប្រភេទមុខវិជ្ជា |
|---|---|---|---|
| 101201 | ទស្សនវិជ្ជាអប់រំ | ២(២-០-៤) | មុខវិជ្ជារួមនៃឯកទេស |
| 101202 | ចិត្តវិទ្យា | ៣(៣-០-៦) | មុខវិជ្ជារួមនៃឯកទេស |
| 101203 | គរុកោសល្យ | ៣(៣-០-៦) | មុខវិជ្ជារួមនៃឯកទេស |
| 101401 | សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងរដ្ឋបាលអប់រំ | S/U(២-០-៤) | មុខវិជ្ជាជម្រើស |
| 101204 | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការរៀន និងបង្រៀន | ៣(២-២-៥) | មុខវិជ្ជារួមនៃឯកទេស |
| 101303 | វិធីសាស្ត្របង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ១ * | ៣(២-២-៥) | មុខវិជ្ជាស្នូលនៃឯកទេស |

**ឆមាសទី២**

| លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | ប្រភេទមុខវិជ្ជា |
|---|---|---|---|
| 101205 | ការវាយតម្លៃលទ្ធផលសិក្សា | ៣(៣-០-៦) | មុខវិជ្ជារួមនៃឯកទេស |
| 101402 | ប្រឹក្សាគរុកោសល្យ | ២(២-០-៤) | មុខវិជ្ជាជម្រើស |
| 101301 | ឯកទេស១ * | ៣(២-២-៥) | មុខវិជ្ជាស្នូលនៃ |

| | | | |
|---|---|---|---|
| | | | ឯកទេស |
| 101304 | វិធីសាស្ត្របង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ ២** | ៣(២-២-៥) | មុខវិជ្ជាស្នូលនៃឯកទេស |
| 101305 | វិធីសាស្ត្របង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ ៣*** | ៣(២-២-៥) | មុខវិជ្ជាស្នូលនៃឯកទេស |
| 101901 | កម្មសិក្សា១(សង្កេត និងពាក់កណ្ដាលប្រតិបត្តិ) | ១(០-៣-២) | កម្មសិក្សាប្រតិបត្តិគរុកោលសល្យ |

### ២.៦.២.២- ឆ្នាំទី២

រចនាសម្ព័ន្ធកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតឧត្ដម(បរិញ្ញាបត្រ+២)នៅវិទ្យាស្ថានជាតិអប់រំសម្រាប់សិក្សាឆ្នាំទី២ ត្រូវបានបង្ហាញក្នុងតារាងខាងក្រោម៖

**ឆមាសទី១**

| លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | ប្រភេទមុខវិជ្ជា |
|---|---|---|---|
| 101206 | ស្រាវជ្រាវអប់រំ | ៣(៣-០-៦) | មុខវិជ្ជារួមនៃឯកទេស |
| 101302 | ឯកទេស២** | ៣(២-២-៥) | មុខវិជ្ជាស្នូលនៃឯកទេស |
| 101902 | កម្មសិក្សា២(ប្រតិបត្តិ) | ៣(០-៦-៣) | កម្មសិក្សាប្រតិបត្តិគរុកោលសល្យ |
| 101501 | ការសរសេរនិក្ខេបបទ១ | ៣ | ការសរសេរនិក្ខេបបទ |

**ឆមាសទី២**

| លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | ប្រភេទមុខវិជ្ជា |
|---|---|---|---|
| 101403 | ភាសាអង់គ្លេស ឬភាសាបារាំង | ២(២-០-៤) | មុខវិជ្ជាជម្រើស |
| 101404 | និន្នាការអប់រំ និងការអប់រំពលរដ្ឋពេញលេញ | ២(២-០-៤) | មុខវិជ្ជាជម្រើស |
| 101405 | សិល្បៈ និងវប្បធម៌ខ្មែរ | S/U(១-២-៣) | មុខវិជ្ជាជម្រើស |
| 101502 | ការសរសេរនិក្ខេបបទ២ | ៣ | ការសរសេរនិក្ខេបបទ |

**សម្គាល់៖** -ឯកទេស(*)(**) វិធីសាស្ត្របង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ(*)(**)(***) មាន២០មុខវិជ្ជាឯកទេស រួមមាន អក្សរសាស្ត្រខ្មែរ ភាសាបារាំង ភាសាអង់គ្លេស ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌ពលរដ្ឋវិជ្ជា គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច អគ្គិសនី មេកានិក អេឡិចត្រូនិក ក្សេត្រសាស្ត្រ បសុវប្បកម្ម កែច្នៃអាហារ និងអប់រំកាយ និងកីឡា

-ចិត្តវិទ្យាអប់រំ(ចិត្តវិទ្យាទូទៅ និងចិត្តវិទ្យាអប់រំ) និងគរុកោសល្យ(គរុកោសល្យទូទៅ និងគរុកោសល្យអនុវត្ត)

-ការពង្រឹងមុខវិជ្ជាតាមជំនាញនីមួយៗ ត្រូវរួមបញ្ចូលទាំងឯកទេស វិធីសាស្ត្របង្រៀន និង គរុកោសល្យ( គរុកោសល្យអនុវត្ត )ដោយមានភាពបត់បែន។ ក្នុងករណីគរុនិស្សិតមាន ចំណេះដឹងឯកទេសហើយ ត្រូវផ្តោតការរៀន និងបង្រៀនលើវិធីសាស្ត្របង្រៀន និង ហ្វឹកហ្វឺនគរុកោសល្យ

-សម្រាប់មុខវិជ្ជាសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន-រដ្ឋបាលអប់រំ និងសិល្បៈ-វប្បធម៌ខ្មែរ ជាមុខ វិជ្ជាតម្រូវ តែមិនផ្តល់ក្រេឌីតជូនទេ មានន័យថាបើគរុនិស្សិតប្រឡងជាប់ នឹងទទួលបាន S (satisfied) ឬក្នុងករណីគរុនិស្សិតប្រឡងធ្លាក់នឹងទទួលបាន U (unsatisfied)។

# ជំពូក៣
# គ្រូឧទ្ទេស គម្រោងស្រាវជ្រាវនិក្ខេបបទ និងការវាយតម្លៃ

## ៣.១- គ្រូឧទ្ទេសបង្រៀនមុខវិជ្ជា

គ្រូឧទ្ទេសដែលត្រូវបង្រៀនកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

-មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់លើជំនាញឯកទេសសមស្រប(និក្ខេបបទ) និងមានបទពិសោធគ្រប់គ្រាន់ពាក់ព័ន្ធនឹងមុខវិជ្ជាដែលខ្លួនទទួលបន្ទុកបង្រៀន ហើយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា

-មានសមត្ថភាពក្នុងការប្រើប្រាស់ភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន

-មានចរិយាសម្បត្តិ សីលធម៌ មនសិការវិជ្ជាជីវៈ និងមានភាពជាគ្រូបង្រៀន។

## ៣.២- គ្រូឧទ្ទេសណែនាំគោល និងគ្រូឧទ្ទេសណែនាំរង

**គ្រូឧទ្ទេសណែនាំត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖**

-មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ និងមានបទពិសោធការងារស្រាវជ្រាវយ៉ាងតិច៥ឆ្នាំ

-មានស្នាដៃ និងកិត្តិនាមក្នុងការចុះផ្សាយអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រថ្នាក់ជាតិ តំបន់ និងអន្តរជាតិ

-មានស្មារតីទទួលខុសត្រូវក្នុងការណែនាំការស្រាវជ្រាវវិទ្យាសាស្ត្រ

-មានសមត្ថភាពក្នុងការប្រើប្រាស់ភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន

-មានសីលធម៌រស់នៅល្អ មនសិការវិជ្ជាជីវៈ និងមានភាពជាគ្រូបង្រៀន។

**គ្រូឧទ្ទេសណែនាំគោល និងគ្រូឧទ្ទេសណែនាំរង ត្រូវមានការទទួលខុសត្រូវ៖**

-សម្របសម្រួលការពារគម្រោង និងអត្ថបទស្រាវជ្រាវពិស្តាររបស់អ្នកសិក្សា

-ត្រួតពិនិត្យ និងសម្របសម្រួលការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិ និងតំបន់របស់អ្នកសិក្សា

-សម្របសម្រួលការចូលរួមវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធរបស់អ្នកសិក្សា

-សម្របសម្រួលការធ្វើសិក្ខាសាលាផ្ទាល់ខ្លួនរបស់អ្នកសិក្សា

-ណែនាំ និងពិនិត្យដំណើរការសរសេរនិក្ខេបបទរបស់អ្នកសិក្សា។

## ៣.៣- ការស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទ

កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) តម្រូវឱ្យអ្នកសិក្សាដែលចុះឈ្មោះរៀន សរសេរនិក្ខេបបទ ដើម្បីបញ្ចប់ការសិក្សាដោយផ្អែកលើលក្ខខណ្ឌកំណត់ដោយកម្មវិធីបណ្តុះបណ្តាលនៃវិទ្យាស្ថានជាតិអប់រំ។

### ៣.៣.១- លក្ខណសម្បត្តិសម្រាប់ការស្រាវជ្រាវសរសេរនិក្ខេបបទ

ដើម្បីស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទបាន អ្នកសិក្សាត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

-មានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យា ភាសាជាតិ និងភាសាបរទេស ដើម្បីឈ្វេងយល់ព័ត៌មានសម្រាប់គាំទ្រការងារស្រាវជ្រាវ

-មានចំណេះដឹងស៊ីជម្រៅលើផ្នែកវិធីសាស្ត្របង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ

-មានការស្រាវជ្រាវបានយ៉ាងល្អ

-មានសីលធម៌វិជ្ជាជីវៈក្នុងការងារស្រាវជ្រាវ

-មានសមត្ថភាពគិត វិភាគ និងដោះស្រាយបញ្ហាដែលកើតឡើងក្នុងការងារស្រាវជ្រាវដោយឯករាជ្យ

-មានសុខភាពបរិបូរណ៍ អាចបំពេញការងារបានប្រកបដោយប្រសិទ្ធភាពក្នុងអំឡុងពេលធ្វើការងារស្រាវជ្រាវសរសេរនិក្ខេបបទ។

**៣.៣.២- រយៈពេល**

អ្នកសិក្សាចុះឈ្មោះរៀនក្នុងកម្មវិធីបណ្តុះបណ្តាលនេះ ត្រូវស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទយ៉ាងយូរមុនដំណាច់ឆ្នាំសិក្សាទី១។ គម្រោងស្រាវជ្រាវសរសេរនិក្ខេបបទ ត្រូវទទួលបានការអនុម័តពីគណៈកម្មការយ៉ាងយូរបំផុតមិនឱ្យលើសឆមាសទី១នៃឆ្នាំសិក្សាទី២។

**៣.៣.៣- ចំនួនក្រេឌីតការងារស្រាវជ្រាវ(ការសរសេរនិក្ខេបបទ)**

**ការសរសេរនិក្ខេបបទមានចំនួន៦ក្រេឌីត**

អ្នកសិក្សា តម្រូវឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទ បំពេញលក្ខខណ្ឌនៃការសិក្សា និងតម្រូវឱ្យធ្វើបទបង្ហាញលទ្ធផលស្រាវជ្រាវតាមដំណាក់កាល ដែលកំណត់ក្នុងផែនការបណ្តុះបណ្តាល។

-សម្រាប់មុខវិជ្ជាវិទ្យាសាស្រ្តសង្គម ការសរសេរនិក្ខេបបទ ត្រូវមានចំនួនកំណត់យ៉ាងហោចណាស់ចាប់ពី១០០ទំព័រឡើងទៅ ដោយមិនគិតពីឧបសម្ព័ន្ធ និងឯកសារយោង

-សម្រាប់មុខវិជ្ជាវិទ្យាសាស្រ្តពិត ការសរសេរនិក្ខេបបទ ត្រូវមានចំនួនកំណត់យ៉ាងហោចណាស់ចាប់ពី៦០ទំព័រឡើងទៅ ដោយមិនគិតពីឧបសម្ព័ន្ធ និងឯកសារយោង។

**៣.៣.៤- ការត្រៀម**

ដើម្បីឱ្យកិច្ចដំណើរការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) ទទួលបានលទ្ធផលល្អប្រសើរ គណៈកម្មការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលត្រូវត្រៀមលក្ខណៈដូចខាងក្រោម៖

-តែងតាំង ឬចាត់តាំងគ្រូឧទ្ទេសណែនាំគោល និងគ្រូឧទ្ទេសណែនាំរង សម្រាប់ណែនាំអ្នកសិក្សាស្រាវជ្រាវសរសេរនិក្ខេបបទ

-ក្នុងឆមាសនីមួយៗ អ្នកសិក្សាត្រូវចុះឈ្មោះចូលរៀនមុខវិជ្ជាសរសេរនិក្ខេបបទ។ លក្ខខណ្ឌនៃកម្មវិធីបណ្តុះបណ្តាលតម្រូវឱ្យគរុនិស្សិតស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទ និងរាយការណ៍អំពីវឌ្ឍនភាពការស្រាវជ្រាវជារៀងរាល់ឆមាស ដើម្បីពិនិត្យតាមដានការធ្វើការងាររបស់អ្នកសិក្សា និងដើម្បីធានាបានថា អ្នកសិក្សាអាចបញ្ចប់ការសិក្សាតាមកាលបរិច្ឆេទសិក្សាដូចបានកំណត់។

**៣.៣.៥- ការសរសេរការស្រាវជ្រាវអប់រំ**

គរុនិស្សិតកម្រិតឧត្តម ត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ ក្នុងន័យនេះ គរុនិស្សិតកម្រិតឧត្តមមិនត្រូវចម្លងស្នាដៃរបស់អ្នកដទៃមកធ្វើជាគំនិត ជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង(references) ឬការអនុញ្ញាតពីម្ចាស់ប្រភព។ ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ គរុនិស្សិតនោះនឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សាបច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់វិទ្យាស្ថានជាតិអប់រំ។

**៣.៤- ការវាយតម្លៃការបណ្តុះបណ្តាល**

ការវាយតម្លៃការសិក្សាទូទៅ និងការប្រឡងការពារនិក្ខេបបទ ត្រូវអនុវត្តតាមលក្ខខណ្ឌរបស់វិទ្យាស្ថានជាតិអប់រំ ដែលបានកំណត់ដោយផ្អែកលើសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

### ៣.៤.១- ចំណាត់ថ្នាក់ពិន្ទុ(GPA)

រូបមន្តគណនារកមធ្យមនៃពិន្ទុនិទ្ទេសសរុប(GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប(GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស(Grade Point - P) និងតម្លៃក្រេឌីតនៃមុខវិជ្ជានីមួយៗ (Attempted Credit Value - C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកពីគ្រប់មុខវិជ្ជា។

បន្ទាប់ពីបញ្ចប់ការសិក្សាតាមមុខវិជ្ជានីមួយៗ គរុនិស្សិតត្រូវវាយតម្លៃនូវមុខវិជ្ជា និងគ្រូឧទ្ទេសទទួលបន្ទុក ដើម្បីទទួលGPA។

### ៣.៤.២- អំពីការដាក់ពិន្ទុ និងការដាក់មូលវិចារ

គរុនិស្សិតម្នាក់ៗ ត្រូវតែបញ្ចប់មុខវិជ្ជានីមួយៗ ដែលតម្រូវនៅក្នុងកម្មវិធីបណ្តុះបណ្តាល។ រាល់ការវាយតម្លៃគរុនិស្សិត ត្រូវបានកំណត់តាមរយៈការឱ្យពិន្ទុ និងការដាក់មូលវិចារដូចមានចែងខាងក្រោម៖

**១- ការដាក់ពិន្ទុ** ពិន្ទុត្រូវបានកំណត់ពី ០០.០០ ដល់ ១០០.០០ [មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (Grade Point Average ឬ GPA) ដែលកំណត់ថាជាប់ គឺចាប់ពីមធ្យមពិន្ទុ ៦៥.០០ ឬ GPA 2.50 ឡើងទៅ]។

**២- អំពីការដាក់មូលវិចារ** ការដាក់មូលវិចារត្រូវសមស្របទៅនឹងពិន្ទុដូចខាងក្រោម៖

**តារាងពិន្ទុនិទ្ទេសសរុប និងមូលវិចារ**

| ពិន្ទុតាមកម្រិត | សមាសភាគភាគរយ | សញ្ញាពិន្ទុជាអក្សរ | ការបរិយាយ |
|---|---|---|---|
| ៤.០០ | ៨៥-១០០ | A | ល្អប្រសើរ |
| ៣.៥០ | ៨០-៨៤ | $B^+$ | ល្អណាស់ |
| ៣.០០ | ៧០-៧៩ | B | ល្អ |
| **២.៥០** | **៦៥-៦៩** | **$C^+$** | **ល្អបង្គួរ** |
| ២.០០ | ៥០-៦៤ | C | មធ្យម |
| ១.៥០ | ៤៥-៤៩ | $D^+$ | ខ្សោយ |
| ១.០០ | ៤០-៤៤ | D | ខ្សោយណាស់ |
| ០.០០ | ០-៣៩ | F | ធ្លាក់ |
| **បញ្ជាក់៖** សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់អប់រំវិជ្ជាជីវៈគ្រូបង្រៀនកម្រិតឧត្តម ត្រូវមានពិន្ទុនិទ្ទេសសរុបយ៉ាងតិច ៦៥.០០ (GPA ≥ 2.50) ឬនិទ្ទេស $C^+$ | | | |

ការវាយតម្លៃការសិក្សាទូទៅ ការប្រឡង និងការការពារនិក្ខេបបទ ត្រូវអនុវត្តតាមលក្ខខណ្ឌរបស់វិទ្យាស្ថានជាតិអប់រំ ដែលបានកំណត់ដោយផ្អែកលើសេចក្តីណែនាំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ របស់ក្រសួងអប់រំ យុវជន និងកីឡា។

ការវាយតម្លៃកម្មវិធីបណ្តុះបណ្តាល រួមមាន ការវាយតម្លៃជាដំណាក់(Formative Assessment) និងការវាយតម្លៃបញ្ចប់(Summative Assessment)។

វិធីសាស្ត្រក្នុងការវាយតម្លៃ រួមមាន សំណួរផ្ទាល់មាត់ កិច្ចការផ្ទះ កិច្ចការក្រុម ការរៀបចំគម្រោងស្រាវជ្រាវ ការធ្វើបទបង្ហាញ ការតាំងពិព័រណ៍អប់រំ ការចោទសួរ និងឆ្លើយសំណួរ ការធ្វើកម្មសិក្សាគរុកោសល្យ ការធ្វើថ្នាក់និទស្សន៍ ការសរសេរនិក្ខេបបទ និងការប្រឡងនានា។

តារាងការវាយតម្លៃការបណ្តុះបណ្តាល

| ល.រ. | **ទម្រង់ការវាយតម្លៃ** | **ភាគរយ** (%) |
|---|---|---|
| ១ | វត្តមាន និងការចូលរួមសិក្សាសកម្ម | ១៥ |
| ២ | ការវាយតម្លៃជាដំណាក់ | ៣០ |
| ៣ | ការសរសេររបាយការណ៍គម្រោង | ៣០ |
| ៤ | ប្រឡងបញ្ចប់តាមមុខវិជ្ជា ឬបទបង្ហាញរបាយការណ៍គម្រោង | ២៥ |
| | សរុប | ១០០ |
| គ្រូឧទ្ទេសមានសិទ្ធិក្នុងការរៀបចំរង្វាយតម្លៃតាមមុខវិជ្ជាទទួលបន្ទុកក្នុងភាពបទបែន | | |

**៣.៤.៣- សុចរិតភាពនៃការសិក្សា**

ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល គរុនិស្សិតកម្រិតឧត្តមម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗ ដូចខាងក្រោម៖

**-ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា**

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់គរុនិស្សិតម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្តភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងសាលារៀន និងក្រៅសាលារៀន។

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់គរុនិស្សិតម្នាក់ៗ គឺជាយោបល់ឯកភាពមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់គរុនិស្សិតម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថានជាតិអប់រំ។

**-ការក្លែងបន្លំឯកសារ**

គរុនិស្សិតកម្រិតឧត្តមដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីគរុនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។

**-ការផ្តល់សញ្ញាបត្រ**

គរុនិស្សិតកម្រិតឧត្តម(បរិញ្ញាបត្រ+២) ដែលបានបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យនៅវិទ្យាស្ថានជាតិអប់រំ នឹងទទួលបានសញ្ញាបត្រគរុបរិញ្ញាបត្រជាន់ខ្ពស់អប់រំវិជ្ជាជីវៈគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២)។

# ជំពូក៤
# ការពណ៌នាមុខវិជ្ជា

ការធ្វើបច្ចុប្បន្នកម្មចំណេះដឹង ជំនាញ និងវិធីសាស្ត្ររៀន និងបង្រៀន ដើម្បីប្រើប្រាស់ក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល មានសារៈសំខាន់សម្រាប់គ្រូបង្រៀនកម្រិតឧត្តម។ កម្មវិធីនេះ ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងលើមុខវិជ្ជាឯកទេសចិត្តគរុកោសល្យ ការគ្រប់គ្រងថ្នាក់រៀន វិធីសាស្ត្របង្រៀនថ្មីៗសម្បូរបែប វិធីសាស្ត្រក្នុងការវាយតម្លៃ និងតួនាទីរបស់គ្រូ បង្រៀននៅក្នុងប្រព័ន្ធអប់រំ។

**អត្ថន័យលេខកូដមុខវិជ្ជា**

| **ការសរសេរមុខវិជ្ជា** | | |
|---|---|---|
| **លេខកូដមុខវិជ្ជា** | **ឈ្មោះមុខវិជ្ជា** | **ក្រេឌីត** |
| A-BB-C-DD | មុខវិជ្ជា | ចំនួនក្រេឌីត(X-Y-Z) |
| 2-01-2-01 | គរុកោសល្យ | ៣(២-២-៥) |
| | សិល្បៈ និងវប្បធម៌ខ្មែរ | ២(១-២-៣) |
| 2-01-2-01<br>2-01-1-01 | PEDG EDU | |

**ពណ៌នាលេខកូដ**

| | | |
|---|---|---|
| A **លេខកូដកម្រិតថ្នាក់** | | |
| | ១ | បណ្ឌិត |
| | ២ | បរិញ្ញាបត្រជាន់ខ្ពស់ |
| | ៣ | បរិញ្ញាបត្រ |
| BB **ជំនាញ** | | |
| | ០១ | អប់រំ(បរិញ្ញាបត្រ+២) |
| | ០២ | អប់រំ(បរិញ្ញាបត្រ+១) |
| | ០៣ | គណៈគ្រប់គ្រងសាលារៀន |
| C **បណ្តុំមុខវិជ្ជា** | | |
| | ១ | មូលដ្ឋានគ្រឹះបំពេញបន្ថែម |
| | ២ | មុខវិជ្ជារួមនៃឯកទេស |
| | ៣ | មុខវិជ្ជាស្នូលនៃឯកទេស |
| | ៤ | មុខវិជ្ជាជម្រើស |
| | ៥ | ការស្រាវជ្រាវ |
| | ៩ | កម្មសិក្សា |
| DD **លំដាប់នៃមុខវិជ្ជា** | | |

### ៤.១- មុខវិជ្ជារួមនៃឯកទេស

#### ៤.១.១- ទស្សនវិជ្ជាអប់រំ( Educational Philosophy ) ២( ២-០-៤ )

ទស្សនវិជ្ជាអប់រំសិក្សាទស្សនវិជ្ជាប្រតិបត្តិដែលទាក់ទងទៅនឹងធម្មជាតិ គោលបំណងនៃការអប់រំ បញ្ហាទស្សនវិជ្ជាដែលកើតឡើងពីទ្រឹស្តី និងការអនុវត្តជាក់ស្តែង។ ក្នុងបរិបទនេះ ទស្សនវិជ្ជាអប់រំនឹងផ្តល់ដល់គរុនិស្សិតទាំងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាលើវិស័យអប់រំដែលរួមមានរបៀបនៃការអប់រំមនុស្ស ប្រព័ន្ធនៃទស្សនវិជ្ជាអប់រំ និងទ្រឹស្តីអប់រំទាំងឡាយដែលត្រូវបានសង្គមនីមួយៗក្នុងពិភពលោកជ្រើសរើសយកមកប្រើប្រាស់ក្នុងការដឹកនាំសង្គមជាមួយនឹងទ្រឹស្តីនានានៃការរៀន និងបង្រៀន ការគ្រប់គ្រងការអប់រំ។ គរុនិស្សិត នឹងពិភាក្សា និងស្រាវជ្រាវអំពីធម្មជាតិរបស់មនុស្សដែលសមស្របសម្រាប់ការអប់រំបុគ្គលិកលក្ខណៈ និងសក្តានុពល។ គរុនិស្សិតនឹងវិភាគផងដែរអំពីទ្រឹស្តីទាំងឡាយរបស់ទស្សនវិទូល្បីៗទាក់ទងការអប់រំដូចជា សូក្រាត ប្លាតុង អារីស្តូត ហ្សង់ ហ្សាក់រ៉ូស្សូ ចន ឌូវី ជាដើម។ គរុនិស្សិតសិក្សាទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅក្នុងថ្នាក់ និងនៅក្នុងសង្គម ហើយពួកគេអាចឆ្លុះបញ្ចាំង និងវាយតម្លៃនូវទ្រឹស្តីនានាដែលកំពុងប្រើប្រាស់ក្នុងការអប់រំ ដែលកើតចេញពីការអនុវត្តជាក់ស្តែងនៅក្នុងសង្គម លើនិន្នាការនៃការអប់រំសម័យទំនើបនេះ។

#### ៤.១.២- ចិត្តវិទ្យា( Psychology ) ៣( ៣-០-៦ )

សិក្សាលើច្បាប់របស់បាតុភូតចិត្ត ទ្រឹស្តីនៃចិត្តវិទ្យា និងណែនាំពីការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក្នុងថ្នាក់រៀន និងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ អ្នកសិក្សាចូលរួមយ៉ាងសកម្មឈ្វេងយល់ និងពិភាក្សាស៊ីជម្រៅលើទិដ្ឋភាពទូទៅនៃចិត្តវិទ្យាអប់រំ សារៈប្រយោជន៍នៃចិត្តវិទ្យាក្នុងវិស័យអប់រំ ការអភិវឌ្ឍបុគ្គលិកលក្ខណៈវ័យជំទង់ រចនាសម្ព័ន្ធបុគ្គលិកលក្ខណៈ ការអភិវឌ្ឍអត្តសញ្ញាណ សីលធម៌របស់សិស្ស ការអភិវឌ្ឍមុខងារប្រព័ន្ធប្រសាទ និងលំនាំក្នុងការចាប់យកចំណេះដឹង( ពុទ្ធិឥន្ទ្រីយ៍ និងពុទ្ធិវិចារ ) បញ្ហាសុខភាពផ្លូវចិត្តរបស់ជំទង់ និងការអន្តរាគមន៍ក្នុងតួនាទីជាគ្រូបង្រៀន។

#### ៤.១.៣- គរុកោសល្យ( Pedagogy ) ៣( ៣-០-៦ )

សិក្សាលើបញ្ហាទូទៅនៃគរុកោសល្យ ទ្រឹស្តីនានានៃវិធីបង្រៀន ការយល់ដឹងពីរបៀបរៀន និងការគិតរបស់សិស្ស ទ្រឹស្តីនៃវិធីបង្រៀនតាមបែបដោះស្រាយបញ្ហា វិធីសាស្ត្រជំរុញលើកទឹកចិត្តសិស្ស យល់ដឹងអំពីខ្លឹមសារនៃការបង្រៀន លំនាំនៃការបង្រៀន និងគោលការណ៍នៃការបង្រៀនជាដើម។ អ្នកសិក្សាចេះផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងនៅក្នុងថ្នាក់រៀនក៏ដូចជាជីវភាពរស់នៅប្រចាំថ្ងៃ ក្នុងគោលបំណងធ្វើឱ្យការរៀន និងការបង្រៀនប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីឆ្លើយតបទៅនឹងបរិបទថ្មីនៃការអប់រំក្នុងយុគសម័យទំនើប។ ជាពិសេសអ្នកសិក្សានឹងអាច**ឈ្វេង**យល់ពីច្បាប់ស្តីពីការអប់រំគោលនយោបាយ និងគោលដៅអប់រំជាតិ វិធីសាស្ត្របង្រៀន និងការអប់រំនានាដែលពាក់ព័ន្ធទៅនឹងវិស័យអប់រំ។

#### ៤.១.៤- ស្រាវជ្រាវអប់រំ( Educational Research ) ៣( ៣-០-៦ )

មុខវិជ្ជាស្រាវជ្រាវអប់រំ សិក្សាអំពីការស្រាវជ្រាវតាមបែបគុណវិស័យ បរិមាណវិស័យ ចម្រុះ និងប្រតិបត្តិ ដើម្បីយកវិធីសាស្ត្រស្រាវជ្រាវអប់រំទៅអនុវត្តក្នុងការសរសេរសារណាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងធ្វើការស្រាវជ្រាវតាមឯកទេសនីមួយៗលើប្រធានបទដែលទាក់ទងទៅនឹងការអប់រំ។ គរុនិស្សិតអនុវត្តយន្តការនៃការស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រ។

### ៤.១.៥- បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការរៀន និងបង្រៀន (Digital Portfolio) ៣(២-២-៥)

មុខវិជ្ជាកុំព្យូទ័រទូទៅ(Digital Portfolio) គឺសិក្សាទៅលើទ្រឹស្តី និងការអនុវត្តផ្ទាល់លើកម្មវិធីថ្មីៗ ដែលផ្តោតលើការពង្រឹងសមត្ថភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា និងសារគមនាគមន៍ ក្នុងសិក្សារៀនសូត្រ និងការស្រាវជ្រាវ។ គរុនិស្សិត នឹងអនុវត្តការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីសម្រមខ្លួនទៅតាមការផ្លាស់ប្តូរនៃពិភពលោកក្នុងការទ្រទ្រង់ការរៀន និងបង្រៀនពីចម្ងាយប្រកបដោយប្រសិទ្ធភាព។

### ៤.១.៦- ការវាយតម្លៃលទ្ធផលសិក្សា(Assessment) ៣(៣-០-៦)

មុខវិជ្ជានេះ សិក្សាពីបញ្ញត្តិទូទៅជាមូលដ្ឋាននៃការវាយតម្លៃ ការបង្កើតវិញ្ញាសាតេស្តសម្រាប់វាយតម្លៃការសិក្សារបស់សិស្ស ភាពខុគ្នានៃការវាយតម្លៃការអប់រំ និងការវាយតម្លៃក្នុងថ្នាក់ ព្រមទាំងរបៀបនៃការបង្កើតតេស្ត។ ទំនាក់ទំនងរវាងសំណួរតេស្ត ការវិភាគជាតុនៃសំណួរតេស្ត ការបង្រៀនដែលផ្អែកលើសមត្ថភាព និងការធ្វើតេស្ត និងរបៀបនៃការបន្សីគ្នាពីវត្ថុបំណងនៃកម្មវិធីសិក្សាទៅនឹងលទ្ធផលរំពឹងទុកនៃការសិក្សា ក៏ត្រូវបានលើកយកមកបង្ហាញ និងអនុវត្តក្នុងកំឡុងពេលវគ្គសិក្សា ដើម្បីឱ្យគរុនិស្សិតមានទស្សនៈទូលំទូលាយ និងអភិវឌ្ឍការវាយតម្លៃការសិក្សារបស់សិស្ស។

## ៤.២- មុខវិជ្ជាស្នូលនៃឯកទេស

មុខវិជ្ជានេះ បណ្តុះឥរិយាបថជាវិជ្ជមានដល់គ្រូបង្រៀនកម្រិតឧត្តម ក្នុងការលើកកម្ពស់ចំណេះដឹង និងបំណិនឯកទេស ស្របតាមកម្មវិធីបណ្តុះបណ្តាលនៅសាលាមធ្យមសិក្សាទុតិយភូមិ ដោយប្រើប្រាស់សម្ភារឧបទេស និងវិធីសាស្ត្របង្រៀនសតវត្សរ៍ទី២១ តាមរយៈការសរសេរកិច្ចតែងការបង្រៀនតាមឯកទេសនីមួយៗ ឱ្យមានប្រសិទ្ធភាពក្នុងការអនុវត្តជាក់ស្តែងនៅថ្នាក់រៀនដោយផ្សារភ្ជាប់ការរៀន និងបង្រៀន ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ ឯកទេសនីមួយមានចំនួន៦ក្រេឌីត និងនិស្សិតត្រូវសិក្សាចំនួន៣ក្រេឌីត តាមទម្រង់ ៣(២-២-៥) ចំនួន២ឆមាស។

### ៤.២.១- ឯកទេសតាមមុខវិជ្ជានីមួយៗ

#### ៤.២.១.១- អក្សរសាស្ត្រខ្មែរ(Khmer Literature) (៦ក្រេឌីត)

គរុនិស្សិតនឹងសិក្សាអំពីទ្រឹស្តី បញ្ញត្តិ ទស្សនៈ និងការប្រតិបត្តិនៃមុខវិជ្ជានីមួយៗក្នុងថ្នាក់ បណ្ណាល័យ សាលាហាត់ការ សាលាសហការជាដើម។ មុខវិជ្ជានេះផ្តោតលើការពង្រីកសមត្ថភាពរបស់គរុនិស្សិតក្នុងការសិក្សារៀនសូត្រ និងការស្រាវជ្រាវ ឱ្យកាន់តែស៊ីជម្រៅ។ គរុនិស្សិតម្នាក់ៗចេះវិភាគវែកញែក ប្រៀបធៀប រកហេតុផល ខុសត្រូវ មានគំនិតច្នៃប្រឌិត សំយោគគំនិត និងការបង្កើតថ្មីបានសមស្របតាមស្ថានភាពជាក់ស្តែង។ ពួកគេនឹងក្លាយជាគ្រូបង្រៀនកម្រិតឧត្តមប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងមានវិជ្ជាជីវៈក្នុងការរៀន និងបង្រៀនអក្សរសាស្ត្រខ្មែរ តាមបែបសកម្មស្របតាមទ្រឹស្តីបែបស្ថាបនានិយមដែលឆ្លើយតបទៅនឹងស្តង់ដាគ្រូបង្រៀនសតវត្សរ៍ទី២១។

#### ៤.២.១.២- ភាសាបារាំង(French) (៦ក្រេឌីត)

គរុនិស្សិតត្រូវសិក្សាសមត្ថភាពទំនាក់ទំនងទាំង៤នៃភាសាបារាំង រួមមានសមត្ថភាពអាន សមត្ថភាពស្តាប់ សមត្ថភាពនិយាយ និងសមត្ថភាពសរសេរ ស្របតាមឯកសារយោងសម្រាប់ក្របខណ្ឌអឺរ៉ុបទូទៅ (CECRL) កម្រិតDELF B2 ដោយផ្តោតលើប្រធានបទមួយចំនួន ដូចជាការអប់រំ សេដ្ឋកិច្ច មធ្យោបាយធ្វើដំណើរ ទំនាក់ទំនង ជាដើម។ គរុនិស្សិតត្រូវចូលរួមឈ្វេងយល់អំពីសំឡេង ស្រង់ព័ត៌មាន កត់ត្រាព័ត៌មាន

ពន្យល់ពីព័ត៌មាន និងអានអត្ថបទប្រកបដោយប្រសិទ្ធភាព ឆ្លើយសំណួរ សរសេរអត្ថបទផ្សេងៗ ពិភាក្សា និងស្រាវជ្រាវបន្ថែមទៀត ដើម្បីអភិវឌ្ឍភាសាបារាំងរបស់ខ្លួន។

### ៤.២.១.៣- ភាសាអង់គ្លេស(English) (៦ក្រេឌីត)

សិក្ខាកាម នឹងទទួលបានការបំពាក់បំប៉ន ចំណេះដឹង ជំនាញ និងបទពិសោធន៍ ក្នុងការបង្រៀនភាសាអង់គ្លេសស្របទៅតាមកម្មវិធីសិក្សាភាសាអង់គ្លេសនៅវិទ្យាល័យនិងបរិបទប្រទេស កម្ពុជា។ សិក្ខាកាមទាំងអស់ នឹងសិក្សាភាសាអង់គ្លេស ដោយផ្តោតទៅលើ ប្រព័ន្ធភាសាដែលមានដូចជា រូបសព្ទវិទ្យា សូរវិទ្យា វេយ្យាករណ៍ មុខងារភាសា វាក្យសព្ទ និងជំនាញគ្រឹះទាំងបួនរួមមាន ជំនាញអាន ជំនាញសរសេរ ជំនាញស្តាប់ និងជំនាញនិយាយ។ បន្ទាប់ពីបញ្ចប់វគ្គសិក្សានេះ សិក្ខាកាម ក៏នឹងអាចអភិវឌ្ឍនិងពង្រីកកម្រិតចំណេះដឹងនិងជំនាញភាសាអង់គ្លេស ព្រមទាំងយល់ច្បាស់ពីកត្តា និងមូលហេតុអ្វីដែលអាចឲ្យពួកគេបង្រៀនប្រកបដោយសមត្ថភាពនិងប្រសិទ្ធភាពខ្ពស់។

### ៤.២.១.៤- ប្រវត្តិវិទ្យា(History) (៦ក្រេឌីត)

គរុនិស្សិតសិក្សាអំពីអត្តសញ្ញាណជាតិ វប្បធម៌ ប្រពៃណី ច្បាប់ នយោបាយកម្ពុជាជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក ព្រមទាំងដំណើរវិវត្តនៃស្ថានភាពសង្គម និងទិដ្ឋភាពសំខាន់ៗនៃជីវភាពប្រចាំថ្ងៃរបស់ប្រជាជន តាមសម័យកាលនីមួយៗ និងទំនាក់ទំនងអន្តរជាតិក្រោយសង្គ្រាមលោកលើកទី២ ដែលផ្តោតលើការពង្រីកសមត្ថភាពក្នុងការសិក្សារៀនសូត្រ និងការស្រាវជ្រាវបែបវិទ្យាសាស្ត្រលើប្រវត្តិសាស្ត្រឱ្យកាន់តែស៊ីជម្រៅ។ គរុនិស្សិតត្រូវធ្វើការសិក្សាស្រាវជ្រាវពីប្រភពឯកសារបណ្ណសារ ផែនទី សារព័ត៌មាន ឯកសារស្នាដៃ សោតទស្សន៍ បុរាណវត្ថុ ដើម្បីវិភាគ ប្រៀបធៀប និងសន្និដ្ឋានពីដំណើរប្រព្រឹត្តទៅនៃសង្គម សេដ្ឋកិច្ច នយោបាយក្នុងប្រវត្តិសាស្ត្រ។

### ៤.២.១.៥- ភូមិវិទ្យា(Geography) (៦ក្រេឌីត)

គរុនិស្សិតសិក្សាអំពីទ្រឹស្តី ខ្លឹមសារ រូបមន្ត បាតុភូតធម្មជាតិ និងបាតុភូតសង្គមនានាដែលពាក់ព័ន្ធភូមិវិទ្យា ដើម្បីពង្រឹងសមត្ថភាពសម្រាប់យកទៅប្រើប្រាស់ក្នុងអាជីពរបស់ខ្លួនក្នុងការបង្រៀន។ ក្នុងការសិក្សា គរុនិស្សិតត្រូវធ្វើការងារជាបុគ្គល ក្រុម សិក្សាស្រាវជ្រាវ ឬបង្កើតគម្រោងដើម្បីដោះស្រាយបញ្ហាក្នុងសហគមន៍ និងធ្វើបទបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវឬគម្រោងទាំងនោះ។ គរុនិស្សិតផលិតសម្ភារៈសម្រាប់បង្រៀន បង្កើតវីដេអូបង្រៀន និងអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

### ៤.២.១.៦- សីលធម៌ពលរដ្ឋវិជ្ជា(Moral Civics) (៦ក្រេឌីត)

សិក្សាផ្អែកលើកម្មវិធីសិក្សាទុតិយភូមិដែលរួមបញ្ចូលទាំងទិដ្ឋភាពច្បាប់ សង្គមសេដ្ឋកិច្ច វប្បធម៌ ប្រពៃណី សីលធម៌សង្គម ទំនៀមទំលាប់ខ្មែរ ទស្សនវិជ្ជាសង្គមនយោបាយ ទ្រឹស្តីពុទ្ធិ និងទស្សនវិជ្ជាអប់រំ។ គរុនិស្សិតធ្វើការវិភាគស៊ីជម្រៅ និងវាយតម្លៃអំពីសង្គម សេដ្ឋកិច្ច និងនយោបាយ ជាពិសេសពួកគេ ប្រែក្លាយឥរិយាបទរបស់ខ្លួនជាពលរដ្ឋល្អក្នុងសង្គម មានស្មារតីជួយគ្នា ចេះប្រើប្រាស់ការប្រាស្រ័យទាក់ទងយ៉ាងមានប្រសិទ្ធភាព គោរពសិទ្ធិអ្នកដទៃ ចេះរួមរស់ជាមួយគ្នាក្នុងសង្គមប្រកបដោយសុខដុមរមនា។

### ៤.២.១.៧- គណិតវិទ្យា(Mathematics) (៦ក្រេឌីត)

គរុនិស្សិត នឹងសិក្សាខ្លឹមសារមេរៀន រូបមន្ត និងបង្កើតលំហាត់ទាក់ទងនិងជីវភាពរសនៅជាក់ស្តែង។ គរុនិស្សិតកំណត់បានពីរបៀបបង្កើតសម្ភារឧបទេសងាយៗក្នុងការបង្រៀន ហើយចេះរៀបចំសកម្មភាពបង្រៀនលើមុខវិជ្ជាឯកទេសរបស់ខ្លួនបានយ៉ាងស្ទាត់ជំនាញ និងអាចអភិវឌ្ឍ និងពង្រីកកម្រិតចំណេះដឹង ព្រមទាំងយល់ច្បាស់ពីកត្តា និងមូលហេតុអ្វីដែលអាចឱ្យពួកគេបង្រៀនប្រកបដោយសមត្ថភាព និងប្រសិទ្ធភាព

ខ្ពស់។ គរុនិស្សិត នឹងទទួលបានការបំពាក់បំប៉នចំណេះដឹង ជំនាញ និងបទពិសោធន៍ក្នុងការបង្រៀនគណិតវិទ្យាស្របតាមកម្មវិធីសិក្សាគណិតវិទ្យានៅវិទ្យាល័យនៅកម្ពុជា។

**៤.២.១.៨- រូបវិទ្យា (Physics) (៦ក្រេឌីត)**

គរុនិស្សិតសិក្សាខ្លឹមសារទ្រឹស្តីសំខាន់ៗ គោលការណ៍ ច្បាប់ បញ្ញត្តិ បាតុភូត និងរូបមន្ត ដោយផ្សារភ្ជាប់នឹងគណិតវិទ្យា ដើម្បីពង្រឹង និងពង្រីកចំណេះដឹងមូលដ្ឋានរបស់ខ្លួន។ ពួកគេធ្វើបទបង្ហាញដោយសង្ខេបពីអ្វីដែលបានស្រាវជ្រាវរកឃើញ ដោយផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែងនៅក្នុងការរស់នៅក្នុងសង្គម (វិស័យសុខាភិបាល) បរិស្ថាន បច្ចេកវិទ្យា និងវិស្វកម្ម។ គរុនិស្សិតផលិតសម្ភារឧបទេសបង្រៀន ធ្វើពិសោធដោយប្រើប្រាស់សម្ភារៈជាក់ស្តែង និងធ្វើពិសោធន៍តាមE-Laboratory ដោយប្រើកុំព្យូទ័រ ដែលផ្តល់ឱ្យពួកគេនូវបំណិនបន្ថែមលើផ្នែកSTEM ការសរសេរកូដ បំណិនសតវត្សទី២១ ដែលបម្រើឱ្យផ្នែករឹង ផ្នែកទន់ បញ្ញាសិប្បនិម្មិត (Artificial Intelligent) និងបដិវត្តឧស្សាហកម្ម៤.0 សម្រាប់ពួកគេចូលប្រកួតប្រជែងក្នុងទីផ្សារការងារ។

**៤.២.១.៩- គីមីវិទ្យា (Chemistry) (៦ក្រេឌីត)**

មុខវិជ្ជានេះបានផ្តោតលើការពង្រីក និងពង្រឹងសមត្ថភាពរបស់គរុនិស្សិតក្នុងការសិក្សារៀនសូត្រ និងការស្រាវជ្រាវលើឯកទេសគីមីវិទ្យាឱ្យបានកាន់តែស៊ីជម្រៅដែលនាំឱ្យគរុនិស្សិតម្នាក់ៗ ចេះវិភាគវែកញែក ប្រៀបធៀបរកហេតុផល ធ្វើពិសោធន៍ផ្ទៀងផ្ទាត់នៅក្នុងទីពិសោធន៍ជាក់ស្តែង ឬតាម E-Laboratory មានគំនិតច្នៃប្រឌិតក្នុងការបង្រៀន និងការបង្កើតថ្មីតាមបែបវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) បានសមស្របតាមស្ថានភាពជាក់ស្តែង ដែលទាក់ទងទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ គរុនិស្សិតនឹងសិក្សាអំពីទ្រឹស្តី និងការអនុវត្ត ដែលឆ្លើយតបទៅនឹងស្តង់ដាគ្រូបង្រៀនសតវត្សទី២១ ហើយបម្រើឱ្យផ្នែករឹង ផ្នែកទន់ បញ្ញាសិប្បនិម្មិត (Artificial Intelligent) និងបដិវត្តឧស្សាហកម្ម៤.0 សម្រាប់ពួកគេចូលប្រកួតប្រជែងក្នុងទីផ្សារការងារ។

**៤.២.១.១០- ជីវវិទ្យា (Biology) (៦ក្រេឌីត)**

មុខវិជ្ជាឯកទេសជីវវិទ្យានេះ សិក្សាលើទ្រឹស្តីទូទៅនៃសមាសធាតុគីមីនៃជីវិត មូលដ្ឋានគ្រឹះនៃជីវិត កាយវិភាគវិទ្យាសត្វ អំមេអូស្តាស៊ីស រួមទាំងការសិក្សាទៅលើសេនេទិចមនុស្ស មូលដ្ឋានគ្រឹះនៃម៉ូលេគុលតំណពូជ ទស្សនវិជ្ជារបស់លោកដាវីន និងដំណើរការនៃការគ្រប់គ្រងទីពិសោធ។ គរុនិស្សិត នឹងសិក្សាអំពីទ្រឹស្តី ការអនុវត្ត និងការធ្វើពិសោធ ដែលឆ្លើយតបទៅនឹងស្តង់ដាគ្រូបង្រៀនសតវត្សទី២១ ហើយបម្រើឱ្យផ្នែករឹង ផ្នែកទន់ បញ្ញាសិប្បនិម្មិត (Artificial Intelligent) និងបដិវត្តឧស្សាហកម្ម៤.0 សម្រាប់ពួកគេចូលប្រកួតប្រជែងក្នុងទីផ្សារការងារ។

**៤.២.១.១១- ផែនដីវិទ្យា (Earth Science) (៦ក្រេឌីត)**

គរុនិស្សិតនឹងសិក្សាពីលក្ខណៈពិសេស និងអន្តរកម្មរវាងផ្នែករឹងរបស់ផែនដី បរិយាកាស លំហទឹក និងជីវិតលើភពផែនដី។ គរុនិស្សិតនឹងប្រើប្រាស់ការអង្កេតបែបវិទ្យាសាស្ត្រក្នុងមន្ទីរពិសោធ វិធីសាស្ត្ររុករក ការសិក្សាគំរូពិត និងសិប្បនិម្មិត អំណាន និងការបកស្រាយទិន្នន័យរួមជាមួយនឹងសម្ភារៈ និងវិធីសាស្ត្រសាមញ្ញៗ ដើម្បីស្វែងយល់អំពីផែនដី និងបរិស្ថាន។ តាមរយៈវគ្គសិក្សានេះ គរុនិស្សិតនឹងអភិវឌ្ឍចំណេះកាន់តែជ្រៅជ្រះលើជំនាញឯកទេសដើម្បីត្រៀមខ្លួនក្លាយជាគ្រូបង្រៀនផ្នែកផែនដី និងបរិស្ថានវិទ្យាដ៏ល្អម្នាក់នៅថ្ងៃអនាគត។

### ៤.២.១.១២- ព័ត៌មានវិទ្យា(IT) (៦ក្រេឌីត)

មុខវិជ្ជាឯកទេសព័ត៌មានវិទ្យា គឺសិក្សាទៅលើទ្រឹស្តីនៃសង្គមឌីជីថលកម្ពុជា និងគោលនយោបាយស្តីពីបច្ចេកវិទ្យាព័ត៌មានវិទ្យា និងសារគមនាគមន៍(ICT) ដែលផ្តោតលើការពង្រឹងសមត្ថភាពឱ្យកាន់ស៊ីជម្រៅទៅក្នុងការបង្កើត និងប្រើប្រាស់បច្ចេកវិទ្យាថ្មីៗក្នុងយុគសម័យឌីជីថលសម្រាប់សិក្សារៀនសូត្រនិងការស្រាវជ្រាវ ហើយថែមទាំងចេះយកបច្ចេកវិទ្យាព័ត៌មានវិទ្យា និងសារគមនាគមន៍ មកប្រើប្រាស់សម្រាប់គ្រប់គ្រងការរៀន និងបង្រៀន និងបង្កើតនូវកម្មវិធីថ្មីៗ។ គរុនិស្សិតនឹងធ្វើការស្រាវជ្រាវ និងអនុវត្តទៅលើការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់គ្រប់គ្រងក្នុងការរៀន និងបង្រៀនតាមបែបសកម្មស្របតាមទ្រឹស្តីបែបស្ថាបនានិយម ដែលឆ្លើយតបទៅនឹងស្តង់ដាគ្រូបង្រៀនសតវត្សរ៍ទី២១។

### ៤.២.១.១៣- សេដ្ឋកិច្ចវិទ្យា(Economics) (៦ក្រេឌីត)

គរុនិស្សិតសិក្សាអំពីទិដ្ឋភាពទូទៅនៃបញ្ហាក្នុងមីក្រូសេដ្ឋកិច្ច ពោលគឺបញ្ហាដែលកើតមានក្នុងជីវភាពប្រចាំថ្ងៃទាក់ទងនឹងការកំណត់តម្លៃ តម្រូវការ ការផ្គត់ផ្គង់ ឥរិយាបថរបស់បុគ្គល គ្រួសារ និងក្រុមហ៊ុន ផលប៉ះពាល់របស់តម្លៃ តម្រូវការ និងការផ្គត់ផ្គង់ទំនិញ និងសេវាកម្ម។ គរុនិស្សិតក៏នឹងសិក្សាពីទិដ្ឋភាពទូទៅនៃបញ្ហាម៉ាក្រូសេដ្ឋកិច្ចសម្រាប់ការកំណត់លទ្ធផល ភាពអត់ការងារធ្វើ អត្រាការប្រាក់ អតិផរណា គោលនយោបាយរូបិយវត្ថុ សារពើពន្ធ បំណុលសាធារណៈ និងបញ្ហាសេដ្ឋកិច្ចអន្តរជាតិ។ គរុនិស្សិត នឹងពិភាក្សា វិភាគ វែកញែក ស្រាវជ្រាវ និងធ្វើបទបង្ហាញលើកិច្ចការស្រាវជ្រាវនានា។

### ៤.២.១.១៤- អគ្គិសនី(Electricity) (៦ក្រេឌីត)

ឯកទេសអគ្គិសនី ត្រូវបានចាត់ជាឯកទេសស្នូលនៃបច្ចេកទេស ហើយក៏ជាមុខវិជ្ជាគ្រឹះមួយក្នុងការរុញច្រាននូវកំណើនសេដ្ឋកិច្ចជាតិ។ អ្នកសិក្សានឹងត្រូវធ្វើការសិក្សាទៅលើការវិភាគ ការបញ្ជូន ការគ្រប់គ្រងការបញ្ជាគ្រឿងម៉ាស៊ីន និងរចនាអេឡិចត្រូនិកអនុភាព ដោយផ្តោតទៅលើការសិក្សា ស្វែងយល់ ការស្រាវជ្រាវ និងរិះរកដំណោះស្រាយសម្រាប់ការផលិតអគ្គិសនីសម្រាប់ប្រើប្រាស់ជាលក្ខណៈអាជីវកម្ម និងសហគ្រាសតូចធំ។ ការរចនា និងការប្រតិបត្តិការងារគម្រោងដែលគរុនិស្សិត នឹងសម្រេចបាន ត្រូវបានស្វែងឡើងតាមរយៈការសិក្សាតាមបែបបំផុសគំនិត ដោះស្រាយបញ្ហា ដែលទាក់ទងនិងបញ្ហាអគ្គិសនីថ្មីៗ ដែលកើតមានឡើងក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។

### ៤.២.១.១៥- មេកានិក(Mechamics) (៦ក្រេឌីត)

ឯកទេសមេកានិកដែលត្រូវបានចាត់ជាឯកទេសស្នូលនៃបច្ចេកទេស ប្រើគោលការណ៍វិទ្យាសាស្ត្រ និងវិស្វកម្មដែលទាក់ទងជាមួយមនុស្ស ម៉ាស៊ីន សម្ភារៈប្រើប្រាស់នានា និងថាមពលដើម្បីបង្កើនប្រសិទ្ធភាពផលិតកម្ម។ ក្នុងមុខជំនាញនេះអ្នកនឹងសិក្សាបច្ចេកទេសសម្រាប់ផលិតកម្ម ការវិភាគការងារ ទ្រឹស្តី និងគោលការណ៍នៃការបណ្តុះកម្តៅ ដំណើរការនៃការបង្កើតថាមពល ការប្រើប្រាស់ថាមពលផ្សេងៗ ការត្រួតពិនិត្យលើដំណើរការគ្រប់គ្រង ការត្រួតពិនិត្យគុណភាព លក្ខខណ្ឌដំណើរការសុវត្ថិភាព និងការត្រួតពិនិត្យបរិស្ថាន។ គរុនិស្សិតនឹងបញ្ចូលនូវការរចនា និងការអនុវត្តការងារស្រាវជ្រាវលើគម្រោងផ្សេងៗ ព្រមទាំងឧបករណ៍ មេកានិកដែលប្រើប្រាស់នៅក្នុងការផលិតផលិតផល ឬការប្រើប្រាស់ប្រចាំថ្ងៃ ដូចជាទូរទឹកកក ម៉ាស៊ីនត្រជាក់ និងប្រព័ន្ធទឹកជាដើម។

### ៤.២.១.១៦- អេឡិចត្រូនិក (Electronics) (៦ក្រេឌីត)

ឯកទេសអេឡិចត្រូនិច ជាមុខវិជ្ជាមួយដែលធ្វើការទៅលើការច្នៃប្រឌិត រចនា និងបង្កើតសៀគ្វីអេឡិចត្រូនិចថ្មីៗ ដែលបានមកពីផ្សំបញ្ចូលគ្នារវាងចំណេះដឹងវិទ្យាសាស្ត្រ ទាំងទ្រឹស្តី និងបទពិសោធន៍នៃការអនុវត្តជាក់ស្តែង។ គរុនិស្សិត នឹងសិក្សាតាមបែបសកម្មទៅលើការរចនា ការកែលម្អ និងបង្កើតសៀគ្វីអេឡិចត្រូនិច ទាំងអាណាឡូក និងឌីជីថលកម្រិតខ្ពស់ បណ្តាញទំនាក់ទំនងទូរគមនាគមន៍ Internet of Thing សម្រាប់ឧស្សាហកម្មជំនាន់៤.0 និង Embedded System(Arduino កម្រិតខ្ពស់) ដែលផ្តោតសំខាន់ទៅលើការបណ្តុះគំនិតក្នុងការស្រាវជ្រាវ ស៊ីជម្រៅ និងស្វែងរកដំណោះស្រាយ ឱ្យស្របទៅតាមបរិបទនៃការអប់រំសតវត្សទី២១។

### ៤.២.១.១៧- បសុវប្បកម្ម (Animal Husbandry) (៦ក្រេឌីត)

ឯកទេសបសុវប្បកម្ម សិក្សាស៊ីជម្រៅលើសមាសធាតុនៃសារជាតុចិញ្ចឹមក្នុងចំណី និងតួនាទីនៃសមាសធាតុនីមួយៗ សម្រាប់ការលូតលាស់របស់សត្វ តម្លៃ និងតម្រូវការនៃសារជាតុចិញ្ចឹមរបស់ប្រភេទចំណីផ្សេងៗ និងការផ្តល់ចំណីសត្វនឹងត្រូវបានបញ្ចូល រួមទាំងចំណេះដឹងផ្នែកវេជ្ជសាស្ត្រសត្វតូច និងសត្វធំ។ គរុនិស្សិតធ្វើការស្រាវជ្រាវ រៀបចំប្លង់ពិសោធ និងវិធីសាស្ត្រស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រសត្វ និងវេជ្ជសាស្ត្រសត្វ។ ជាងនេះទៅទៀត គរុនិស្សិតនឹងសរសេរអត្ថបទវិទ្យាសាស្ត្រ និងបោះពុម្ពអត្ថបទវិទ្យាសាស្ត្រ។

### ៤.២.១.១៨- កសិកម្មសាស្ត្រ (Agronomy) (៦ក្រេឌីត)

គរុនិស្សិតសិក្សាឈ្វេងយល់ជំនាញបច្ចេកទេស ដើម្បីពង្រឹងសមត្ថភាព ចំណេះដឹងបច្ចេកទេស នៃការប្រើប្រាស់ដី ដី ការដាំដុះទូទៅ និងការបង្កាត់ពូជរុក្ខជាតិ សម្រាប់យកទៅអនុវត្តពេលចុះកម្មសិក្សាប្រតិបត្តិ និងពេលបំពេញការងារជាក់ស្តែង។ គរុនិស្សិតការសិក្សាមុខវិជ្ជាទាំងអស់ខាងលើ ធ្វើឱ្យគរុនិស្សិតវិភាគបានពីជម្រៅលើ សមាសធាតុសារជាតុចិញ្ចឹមក្នុងដី និងតួនាទីសមាសធាតុនីមួយៗ សម្រាប់ការលូតលាស់ដំណាំ យល់ដឹងពីបច្ចេកទេសពង្រីកពូជដំណាំ បែងចែកប្រភេទដំណាំទៅរដូវកាលដាំដុះ យល់ដឹងពីវិធីកំចាត់សត្វល្អិតចង្រៃបំផ្លាញ់ដំណាំ ស្វែងយល់យុទ្ធសាស្ត្រទីផ្សារកសិផល រួមទាំងចំណេះដឹងការរៀបចំសហគមន៍ និងដំណោះស្រាយបញ្ហាក្នុងសហគមន៍។ ក្នុងន័យកាត់បន្ថយភាពក្រីក្រក្នុងសង្គម ឆ្ពោះទៅរកស្ថិរភាពសេដ្ឋកិច្ច។

### ៤.២.១.១៩- កែច្នៃអាហារ (Food Processing) (៦ក្រេឌីត)

ឯកទេសកែច្នៃអាហារ សិក្សាលើរបៀបកែច្នៃភេសជ្ជៈ អាហារផ្សេងៗ វិធីសាស្ត្រថែរក្សាទុកចំណីអាហារ និងសំបកវេចខ្ចប់ផ្សេងៗសម្រាប់វេចខ្ចប់ និងថែរក្សាទុកចំណីអាហារដើម្បីឱ្យមានអនាម័យ និងរក្សាគុណភាពផលិតផល។ គរុនិស្សិតនឹងពិភាក្សា ស្រាវជ្រាវ ពិសោធន៍ និងអនុវត្តវិធីសាស្ត្រស្រាវជ្រាវក្នុងការកែច្នៃអាហារផងដែរ។ គរុនិស្សិត ក៏នឹងទទួលបានគោលគំនិតរួមបន្ទាប់ពីបានទទួលការបណ្តុះបណ្តាលដើម្បីសរសេរអត្ថបទវិទ្យាសាស្ត្រ សម្រាប់ធ្វើការបោះពុម្ពអត្ថបទវិទ្យាសាស្ត្រលើការសិក្សាស្រាវជ្រាវទាំងនោះ។

### ៤.២.១.២០- អប់រំកាយ និងកីឡា (Physical Education and Sport) (៦ក្រេឌីត)

ឯកទេសអប់រំកាយ និងកីឡា សិក្សាលើគោលនយោបាយ ទ្រឹស្តី និងឧត្តមានុវត្តនៃការសិក្សាវិជ្ជាជីវៈអប់រំកាយ និងកីឡា។ កញ្ចប់មុខវិជ្ជានេះនឹងតម្រង់ទិសគរុនិស្សិតឱ្យទទួលបាននូវសម្បទាទាំងបួន រួមមានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា សំដៅឆ្លើយតបទៅនឹងគោលនយោបាយអប់រំកាយ និងកីឡាថ្នាក់ជាតិ តំបន់ និងអន្តរជាតិ សម្រាប់ការប្រកួតប្រជែងនានា។

### ៤.២.២- វិធីសាស្ត្របង្រៀន និងហ្វឹកហ្វឺនគរុកោសល្យ(Teaching Methodology and Peer Teaching) ១ ២ និង៣ (៩ក្រេឌីត)

សិក្សាលើទ្រឹស្តី បញ្ញត្តិ គោលការណ៍ និងបំណិនវិជ្ជាជីវៈក្នុងការរៀន និងបង្រៀនតាមបែបសកម្ម និងវិធីសាស្ត្របង្រៀននានាតាមទ្រឹស្តីអប់រំបែបស្ថាបនានិយម ដោយផ្តោតសំខាន់លើគោលវិធីបង្រៀន វិធីសាស្ត្របង្រៀន និងយុទ្ធវិធីបង្រៀន ក៏ដូចជាបច្ចេកទេសក្នុងការបង្រៀននានាដែលក្នុងនោះគរុនិស្សិតត្រូវចូលរួមយ៉ាងសកម្មក្នុងការសិក្សា ការពិភាក្សា ការស្រាវជ្រាវដើម្បីទទួលបាននូវចំណេះដឹង និងជំនាញសតវត្សន៍ទី២១។ គរុនិស្សិត ក៏នឹងសិក្សាលើកម្មវិធីសិក្សានៅមធ្យមសិក្សាទុតិយភូមិ ការវាយតម្លៃការរៀន និងបង្រៀន និងការងារប្រតិបត្តិជាក់ស្តែងតាមរយៈការផលិតសម្ភារឧបទេសរៀននិងបង្រៀន ការកសាងសំណួរតាមកម្រិតគិតទាំង៦របស់ប្លូមតាក់សូណូមី ការសរសេរកិច្ចតែងការបង្រៀនតាមវិធីសាស្ត្ររៀនបែបសកម្ម និងបែបស្ថាបនានិយម ការបញ្ជ្រាបការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងផ្តល់ឱកាសឱ្យគរុនិស្សិតបានអនុវត្តការបង្រៀនជាក់ស្តែងនៅក្នុងថ្នាក់រៀនតាមមុខវិជ្ជាឯកទេសនីមួយៗ ដោយមានការជួយគាំទ្រ និងកែលម្អពីគ្រូឧទ្ទេស។

## ៤.៣- មុខវិជ្ជាជ្រើសរើស

### ៤.៣.១- សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងរដ្ឋបាលអប់រំ(Teacher's Codes of Conduct and Educational Administration) S/U (២ក្រេឌីត)

#### សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន

មុខវិជ្ជានេះសិក្សាពីគោលនយោបាយ ទ្រឹស្តី ស្តង់ដា គុណវុឌ្ឍ បញ្ញត្តិ និយាម និងគោលការណ៍ច្បាប់ទាក់ទងនឹងសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន។ គរុនិស្សិតនឹងពិភាក្សា ស្រាវជ្រាវ និងសរសេរគម្រោងនានាទាក់ទងនឹងក្របខណ្ឌសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន។ មុខវិជ្ជានេះ មានគោលបំណងបណ្តុះបណ្តាលការយល់ដឹងដល់អ្នកសិក្សាអំពីការកសាងសមត្ថភាពគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ឈរលើស្មារតីស្រឡាញ់វិជ្ជាជីវៈគំនិតផ្តួចផ្តើម និងភាពច្នៃប្រឌិត។

#### រដ្ឋបាលអប់រំ

មុខវិជ្ជារដ្ឋបាលអប់រំ សិក្សាពីច្បាប់អប់រំ ការគ្រប់គ្រង និងលិខិតបទដ្ឋាននានា។ គរុនិស្សិតចូលរួមអនុវត្តក្នុងការតាក់តែងលិខិតបទដ្ឋាននានា និងហ្វឹកហាត់ចាត់ចែង និងដឹកនាំគ្រប់គ្រងការងាររដ្ឋបាលអប់រំ ទៅតាមតួនាទី និងភារកិច្ចដែលបានកំណត់ដោយច្បាប់។ សំខាន់ជាងនេះទៅទៀត នៅពេលបញ្ចប់វគ្គសិក្សា គរុនិស្សិតនឹងទទួលបានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដោយគោរពទៅតាមឋានានុក្រមបានល្អត្រឹមត្រូវ។

### ៤.៣.២- សិល្បៈ និងវប្បធម៌ខ្មែរ(Arts and Khmer Culture) S/U(២ក្រេឌីត)

សិក្សាផ្តោតលើការពង្រីកសមត្ថភាព ការគិតពិចារណា ការចូលរួមថែរក្សា និងឈ្វេងយល់វិសាលភាពនៃវប្បធម៌ អរិយធម៌ខ្មែរដែលបានបណ្តុះនូវមែកធាងសំខាន់ៗជាច្រើន ក្នុងការទ្រទ្រង់តម្លៃសង្គមខ្មែរឱ្យរីកចម្រើនប្រកបដោយភាពថ្លៃថ្នូរ។ គរុនិស្សិតបំពេញនូវចំណេះដឹងទូទៅបន្ថែមទៅលើមុខវិជ្ជាឯកទេសដែលបង្ហាញថាវប្បធម៌បណ្តុះបណ្តាលផ្នែកស្មារតី(ចំណេះដឹង) ចំណែកឯសង្គមធម៌បណ្តុះបណ្តាលផ្នែកសម្ភារៈ ដើម្បីឆ្លើយតបនឹងតម្រូវការក្នុងសង្គមតាមរយៈចំណេះដឹង និងឈានធ្វើឱ្យប្រទេសមួយក្លាយជា

ប្រទេសមានអរិយធម៌ខ្ពង់ខ្ពស់តាមរយៈ និមិត្តរូប លក្ខណៈពិសេសតំណាងអត្តសញ្ញាណជាតិ និងសម្បត្តិវប្បធម៌សម្បូរបែបក្នុងប្រទេស។

សិក្សាលើការអប់រំខាងផ្នែកផ្លូវកាយ និងការអប់រំខាងផ្នែកខាងស្មារតី ដែលក្នុងនោះមានសិក្សាផ្នែកទ្រឹស្តីសិល្បៈទូទៅ និងការសិក្សាស្វែងយល់ផ្តោតលើសិល្បៈទស្សនីយភាពរួមមាន សិល្បៈរបាំក្បាច់បុរាណ របាំប្រពៃណី របាំប្រជាប្រិយ ទម្រង់ល្ខោនខ្មែរ ចម្រៀងជាតិ តន្ត្រី និងចម្រៀងបុរាណ ដោយផ្សារភ្ជាប់ជាមួយការអនុវត្តចង្វាក់របាំប្រជាប្រិយខ្មែរ ច្រៀងចម្រៀងជាតិ ចម្រៀងប្រពៃណីបុរាណ ព្រមទាំងការសម្តែងទម្រង់ល្ខោនបុរាណ និងល្ខោនអប់រំខ្លីៗ។

**៤.៣.៣- ប្រឹក្សាគរុកោសល្យ** ( Pedagogical Counselling ) ( **២ក្រេឌីត** )

សិក្សាអំពីទ្រឹស្តី គោលការណ៍ ប្រភេទនៃការប្រឹក្សាគរុកោសល្យ វដ្តនៃការប្រឹក្សាគរុកោសល្យ បញ្ហាប្រឈមផ្សេងៗ និងតួនាទីរបស់អ្នកប្រឹក្សាគរុកោសល្យ។ ក្នុងមុខវិជ្ជាសិក្សានេះផ្តោតសំខាន់ច្រើនទៅលើការអនុវត្តជំនាញបង្រៀន និងជំនាញផ្តល់ប្រឹក្សាគរុកោសល្យ ដូចជា របៀបក្នុងការអង្កេតថ្នាក់រៀន ការវិភាគពីចំណុចល្អ និងចំណុចដែលគួរកែលម្អ របៀបនៃការផ្តល់នូវព័ត៌មានត្រឡប់បែបវិជ្ជមាន និងសកម្មភាពគាំទ្រនានាទៅដល់គរុនិស្សិតក្នុងដំណើរការកម្មសិក្សាប្រតិបត្តិ។

**៤.៣.៤- និន្នាការអប់រំ និងការអប់រំពេញមួយជីវិត** ( Social Contexts of Education and Lifelong Learning ) ( **២ក្រេឌីត** )

មុខវិជ្ជានេះត្រូវបានរៀបចំឡើង ដើម្បីសិក្សាពីបច្ចុប្បន្នភាព បញ្ហាកើតមានផ្សេង និងនិន្នាការដែលមានផលជះដល់ការអប់រំ។ មេរៀនដែលលើកយកមកសិក្សារួមមាន៖ ការអប់រំពលរដ្ឋសកលសម្រាប់សង្គម និងការសិក្សាផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ និងយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលលើការអភិវឌ្ឍមូលធនមនុស្ស កំណែទម្រង់ការអប់រំក្នុងបរិបទនៅកម្ពុជា ការអប់រំពលរដ្ឋពេញលេញ ក្នុងការអប់រំគ្រូបង្រៀន និន្នាការនៃការរៀបចំ និងការអភិវឌ្ឍកម្មវិធីសិក្សា ការលើកកម្ពស់វិជ្ជាជីវៈដើម្បីកសាងសមត្ថភាពជាប្រចាំ ជម្រុញភាពសមស្របនៃការរៀននិងបង្រៀន ទំនើបកម្មឌីជីថល និងការអប់រំក្នុងសតវត្សរ៍ទី២១ និងជម្រុញកិច្ចសហប្រតិបត្តិការសាលារៀន ជាមួយគ្រួសារ និងសហគមន៍។ ការសិក្សាមានភាពបត់បែនទៅតាមមូលដ្ឋានចំណេះដឹងរបស់គរុនិស្សិត និន្នាការអប់រំក្នុងបរិបទជាតិនាពេលបច្ចុប្បន្ន ការផ្លាស់ប្តូរក្នុងវិស័យអប់រំ និងការប្រែប្រួលនៃតម្រូវការតួនាទីអ្នកអប់រំជាដើម។ ការសិក្សាមុខវិជ្ជានិន្នាការអប់រំ និងការអប់រំពលរដ្ឋពេញលេញ គឺផ្តោតសំខាន់ទៅលើការវិភាគ សំយោគ និងបកស្រាយ ដោយឈរលើមូលដ្ឋាននៃឧត្តមានុវត្តក្នុងវិស័យអប់រំ។

**៤.៣.៥- ភាសាបរទេស** ( **បារាំង ឬអង់គ្លេស** ) ( Foreign Languages- French or English ) ( **២ក្រេឌីត** )

**ភាសាបារាំង**

អ្នកសិក្សាត្រូវសិក្សាសមត្ថភាពទំនាក់ទំនងទាំង៤ នៃភាសាបារាំង ដូចជា សមត្ថភាពអាន សមត្ថភាពស្តាប់ សមត្ថភាពនិយាយ និងសមត្ថភាពសរសេរ និងបន្ថែមលើសមត្ថភាពភាសាវិទ្យា( វេយ្យាករណ៍ វាក្យស័ព្ទ សូរវិទ្យា )ទៀត ស្របតាមឯកសារយោងសម្រាប់ភាសាក្របខ័ណ្ឌអឺរ៉ុបទូទៅ( CECRL ) កម្រិត DELF A1 ដោយផ្តោតលើប្រធានបទមួយចំនួន ដូចជាការអប់រំ មធ្យោបាយធ្វើដំណើរ ការទំនាក់ទំនង

ជីវភាពប្រចាំថ្ងៃ។ល។ អ្នកសិក្សាត្រូវចូលរួមស្រង់ព័ត៌មាន ពន្យល់ព័ត៌មាន នឹងអានអត្ថបទប្រកបដោយប្រសិទ្ធភាព ឆ្លើយសំណួរ សរសេរអត្ថបទផ្សេងៗ ពិភាក្សា និងស្រាវជ្រាវបន្ថែមទៀត ដើម្បីអភិវឌ្ឍន៍ភាសាបារាំងរបស់ខ្លួន ក្នុងការទទួលបានចំណេះដឹង បំណិន សីលធម៌ និងទេពកោសល្យខ្ពស់ អាចធ្វើការស្រាវជ្រាវលើឯកសារជាភាសាបារាំង ព្រមទាំងចំណេះដឹងពីអរិយធម៌ និងវប្បធម៌របស់ប្រទេសហ្វ្រង់កូហ្វូនី។

**ភាសាអង់គ្លេស**

កម្មវិធីភាសាអង់គ្លេសទូទៅ ត្រូវបានរចនាឡើងសម្រាប់គរុនិស្សិត ដែលមានកម្រិតភាសាអង់គ្លេសដំបូង។ គរុនិស្សិតសិក្សានៅក្នុងថ្នាក់រៀនផង និងសិក្សាដោយខ្លួនឯងផង។ គរុនិស្សិតត្រូវបានរំពឹងថានឹងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពជាក់លាក់មួយចំនួន រួមមានជំនាញស្ដាប់ ជំនាញអាន ជំនាញនិយាយ ជំនាញសរសេរ និងជំនាញសិក្សា។ មូលដ្ឋានគ្រឹះពីរនៃភាសា ជាអាទិ៍វេយ្យាករណ៍ និងវាក្យសព្ទនឹងត្រូវបានបញ្ចូលជាសំខាន់នៅក្នុងការសិក្សារបស់គរុនិស្សិត។ កម្មវិធីភាសាអង់គ្លេសទូទៅនេះនឹងជួយឱ្យគរុនិស្សិតទទួលបាននូវទំនុកចិត្ត និងភាពស្ទាត់ជំនាញក្នុងការកំសាន្ត ការសិក្សា អាជីវកម្ម ក៏ដូចជាការទំនាក់ទំនងប្រចាំថ្ងៃ។ និយាយជារួម បន្ទាប់ពីចូលរួមវគ្គនេះ ជំនាញភាសាអង់គ្លេសរបស់គរុនិស្សិត នឹងត្រូវបានធ្វើឱ្យប្រសើរឡើងដល់កម្រិតជិតមធ្យមដែលស្មើនឹងក្របខណ្ឌភាសាអឺរ៉ុបទូទៅ B1 ដែលនឹងងាយស្រួលក្នុងការទំនាក់ទំនងប្រចាំថ្ងៃ។

**៤.៤- កម្មសិក្សាគរុកោសល្យ (Practicum) (៤ក្រេឌីត)**

កម្មសិក្សាគរុកោសល្យនេះ មាន៣ដំណាក់កាល ដែលតម្រូវឱ្យគ្រូបង្រៀនកម្រិតឧត្តមសង្កេតថ្នាក់ជាជំនួយការគ្រូណែនាំ និងបង្រៀនជាក់ស្ដែងក្នុងថ្នាក់។ អ្វីដែលសំខាន់បំផុត គ្រូបង្រៀនកម្រិតឧត្តមទទួលបាននូវទំនុកចិត្ត បំណិនគរុកោសល្យ វិធីសាស្ត្របង្រៀន និងស្គាល់លក្ខណៈដោយឡែករបស់សិស្សដើម្បីផ្ដល់ប្រឹក្សា និងសម្របសម្រួលការរៀនរបស់សិស្សប្រកបដោយប្រសិទ្ធផលខ្ពស់។

**៤.៤.១- ការធ្វើកម្មសិក្សាគរុកោសល្យ បាឋកថា សិក្ខាសាលា និងសកម្មភាពផ្សេងៗ**

**៤.៤.១.១- កម្មសិក្សាគរុកោសល្យ**

គរុនិស្សិតកម្រិតឧត្តមតម្រូវឱ្យចុះធ្វើកម្មសិក្សាប្រតិបត្តិគរុកោសល្យចំនួន៤ក្រេឌីត ដោយចែកចេញជាបីដំណាក់កាលៈ

**៤.៤.១.១.១- កម្មសិក្សាសង្កេត និងកម្មសិក្សាពាក់កណ្ដាលប្រតិបត្តិ (១ក្រេឌីត)**

កម្មសិក្សាសង្កេត ផ្ដល់ឱកាសឱ្យកម្មសិក្សាការី ក្នុងការសង្កេតគ្រូណែនាំ ដើម្បីឆ្លុះបញ្ចាំងពីតួនាទីនិងការទទួលខុសត្រូវរបស់គ្រូបង្រៀន។ គរុនិស្សិតតម្រូវឱ្យចុះទៅហ្វឹកហាត់ការបង្រៀននៅតាមវិទ្យាល័យ។

កម្មសិក្សាពាក់កណ្ដាលប្រតិបត្តិ ផ្ដល់បទពិសោធជាក់ស្ដែងដល់កម្មសិក្សាការីក្នុងការធ្វើជាជំនួយការ គ្រូណែនាំក្នុងការរៀបចំកិច្ចតែងការបង្រៀន ការរៀបចំសម្ភារឧបទេស ការគ្រប់គ្រងថ្នាក់ ធ្វើការជំនួយដល់ការបង្រៀនខ្លះៗ និងជួបជាមួយគ្រូត្រួតពិនិត្យ។ គរុនិស្សិតតម្រូវឱ្យចុះទៅហ្វឹកហាត់ការបង្រៀននៅតាមវិទ្យាល័យ។

**៤.៤.១.១.២- កម្មសិក្សាប្រតិបត្តិ** (៣ក្រេឌីត)

កម្មសិក្សាប្រតិបត្តិ ផ្តល់ឱកាសដល់កម្មសិក្សាការី ក្នុងការយកចំណេះដឹង ដែលទទួលបានពីការបណ្តុះបណ្តាលទៅអនុវត្តផ្ទាល់នៅក្នុងថ្នាក់រៀន តាមរយៈការសរសេរកិច្ចតែងការបង្រៀន និងការផ្ទេរចំណេះដឹង ដោយរាប់បញ្ចូលទាំងជំនាញគ្រប់គ្រងថ្នាក់ និងជំនាញវាយតម្លៃផង។

**៤.៤.១.២- សិក្ខាសាលា**

គរុនិស្សិតកម្រិតឧត្តមតម្រូវឱ្យចូលរួមសិក្ខាសាលាយ៉ាងតិច២ដង ក្នុងរយៈពេលនៃការបណ្តុះបណ្តាល។

**៤.៤.១.៣- បាឋកថា**

គរុនិស្សិតកម្រិតឧត្តមតម្រូវឱ្យចូលរួមស្តាប់បាឋកថាតាមការចាត់តាំងរបស់វិទ្យាស្ថានជាតិអប់រំ។

**៤.៤.១.៤- ទស្សនកិច្ចសិក្សា**

គរុនិស្សិតកម្រិតឧត្តមតម្រូវឱ្យធ្វើទស្សនកិច្ចសិក្សាតាមការចាំបាច់។

**៤.៤.១.៥- ការតាំងពិព័រណ៍អប់រំ**

គរុនិស្សិតកម្រិតឧត្តមតម្រូវឱ្យមានការស្រាវជ្រាវ និងយកលទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួនមកធ្វើការតាំងពិព័រណ៍អប់រំ ឬបង្ហាញស្នាដៃស្រាវជ្រាវក្នុងសន្និសីទជាតិ ឬអន្តរជាតិ។

**៤.៤.១.៦- សកម្មភាពផ្សេងៗ**

សម្រាប់ម៉ោងដែលនៅសេសសល់ពីការរៀននៅក្នុងថ្នាក់ គរុនិស្សិតតម្រូវឱ្យធ្វើការងារមួយចំនួនទៀត ដើម្បីបង្គ្រប់លក្ខខណ្ឌនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមរួមមាន៖ កិច្ចការស្រាវជ្រាវ ការសរសេរកិច្ចតែងការបង្រៀន ការថតឃ្លីបវីដេអូពីសកម្មភាពនៃការបង្រៀនរបស់គរុនិស្សិត និងការចុះហ្វឹកហាត់ការបង្រៀនតាមវិទ្យាល័យ។

## ៤.៥- មុខវិជ្ជាតម្រូវ (Required Courses)

សិក្ខាសាលា និងបាឋកថា (Workshops and Lectures)

គ្រូបង្រៀនកម្រិតឧត្តមតម្រូវឱ្យចូលរួមស្តាប់សិក្ខាសាលា និងបាឋកថានានាពីថ្នាក់ដឹកនាំ និងវាគ្មិនល្បីៗ ដើម្បីជាទុន និងជាឧត្តមានុវត្តក្នុងវិជ្ជាជីវៈគ្រូបង្រៀន និងជាមូលធនមនុស្សក្នុងការចូលរួមអភិវឌ្ឍសហគមន៍ និងប្រទេសជាតិប្រកបដោយចីរភាព។

## ៤.៦- ម៉ោងសិក្សាបន្ថែម (Extra Curricula Activities)

ម៉ោងសិក្សាបន្ថែមមានបីកញ្ចប់បំណិនរួមមាន៖

១- កិច្ចការស្រាវជ្រាវតាមមុខវិជ្ជាឯកទេសនីមួយៗ

២- ការសរសេរកិច្ចតែងការបង្រៀនតាមមុខវិជ្ជាឯកទេសនីមួយៗ

៣- ការថតឃ្លីបវីដេអូពីសកម្មភាពនៃការបង្រៀនរបស់គរុនិស្សិតម្នាក់ៗ។

ម៉ោងសិក្សាបន្ថែមសម្រាប់គ្រូបង្រៀនកម្រិតឧត្តម ផ្តោតលើបីកញ្ចប់បំណិនរួមមាន៖ កិច្ចការស្រាវជ្រាវ ការសរសេរកិច្ចតែងការបង្រៀន ការថតឃ្លីបវីដេអូពីសកម្មភាពនៃការបង្រៀនតាមមុខវិជ្ជាឯកទេសនីមួយៗ និងសកម្មភាពចាំបាច់ផ្សេងៗទៀត។ល។ ដើម្បីឱ្យគ្រូបង្រៀនកម្រិតឧត្តមមានឱកាសអភិវឌ្ឍសមត្ថភាពសតវត្សរ៍ទី២១ ដែលក្នុងនោះមានចំណេះដឹង និងជំនាញលើមុខវិជ្ជាឯកទេស វិធីសាស្ត្របង្រៀន និងការផលិតសម្ភារឧបទេសរបស់គរុនិស្សិត ជាការចាំបាច់។

# ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា(២០១៦) *ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលចំណេះទូទៅ និងអប់រំបច្ចេកទេស* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៦) *ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៧) *ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ នៅវិទ្យាស្ថានគរុកោសល្យ* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៩) *គម្រោងកែលម្អអប់រំនៅមធ្យមសិក្សា កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន* ភ្នំពេញ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

វិទ្យាស្ថានជាតិអប់រំ(២០២០) *ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១)* ភ្នំពេញ វិទ្យាស្ថានជាតិអប់រំ។

វិទ្យាស្ថានជាតិអប់រំ(២០១៨) *ផែនការយុទ្ធសាស្ត្រវិទ្យាស្ថានជាតិអប់រំ២០១៩-២០២៣* ភ្នំពេញ វិទ្យាស្ថានជាតិអប់រំ។

វិទ្យាស្ថានជាតិអប់រំ(២០១៩) *បទបញ្ញត្តិស្តីពីការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១)* ភ្នំពេញ វិទ្យាស្ថានជាតិអប់រំ។

វិទ្យាស្ថានជាតិអប់រំ(២០១៩) *ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលគរុនិស្សិតកម្រិតឧត្តម(បរិញ្ញា+១) ជំនាន់ទី២៥* ភ្នំពេញ វិទ្យាស្ថានជាតិអប់រំ។

វិទ្យាស្ថានជាតិអប់រំ(២០១៩) *សេចក្តីជូនដំណឹងស្តីពីការប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) សម្រាប់ឆ្នាំសិក្សា២០១៩-២០២០* ភ្នំពេញ វិទ្យាស្ថានជាតិអប់រំ។

វិទ្យាស្ថានជាតិអប់រំ(២០២០) *ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១)* ភ្នំពេញ វិទ្យាស្ថានជាតិអប់រំ។

គណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (២០០៤) *ការអនុវត្តកម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីត* ភ្នំពេញ គណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា (២០១៤) *ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា* ភ្នំពេញ រាជរដ្ឋាភិបាលកម្ពុជា។

SEAMEO. (2018). *Competency Framework for Southeast Asian Teachers*. Bangkok: Teachers' Council of Thailand.

National Institute of Education International. (2019). *Postgraduate Diploma in Education (PGDE) Programme Handbook*. Singapore: National Institute of Education International.

National Institute of Education international. (2020). *Report on the Review of NIE-C's PRESETT and INSETT Curriculums*. Singapore: National Institute of Education International.

Ministry of Education. (2007). *New Zealand Curriculum*. Wellington: Learning Media Limited.

SEAMEO INNOTECH. (2010). *Teaching Competency Standards in Southeast Asian Countries.* Philippines: Regional Education Project Series.

AsTEN. (2017). *The Proposed Teacher Education Standards and Teacher Education Qualification Framework for Teacher Education Institutions in ASEAN*. Indonesia: AsTEN.

Andreas, S. (2016). *Teaching Excellence through Professional Learning and Policy Reform*. Paris: OEDC Publishing.

Andreas, S. (2012). *Preparing teachers and Developing School Leaders for the 21st Century*. Paris: OEDC Publishing.

Oon S. T. et al. (2019). *Teacher Education in 21st Century*. Singapore: Springer.